# ហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត
























# Political Campaign Finance

# មាតិកា

ទំព័រ

**១.សេចក្ដីផ្ដើម**..........1
**២.អនុសាសន៍របស់ខុមហ្វ្រែល**..........4
1. ធ្វើច្បាប់ថ្មី ស្ដីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត
2. វិសោធនកម្ម ស្ដីពីហិរញ្ញវត្ថុសម្រាប់ការឃោសនាទៅក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ឬក្រុមប្រឹក្សាឃុំ-សង្កាត់
3. វិសោធនកម្មលើបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រឆ្នាំ២០០៨ ឬការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧

**៣.របាយការណ៍សង្ខេបក្នុងសិក្ខាសាលាស្ដីពី ហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត**..........10
**៤.ករណីសិក្សា**..........16
ប្រទេសអាហ្សានីស្ថាន..........16
ប្រទេសឥណ្ឌូនេស៊ី..........23
ប្រទេសបារាំង..........28
ប្រទេសកាណាដា..........32
ប្រទេសអាមេរិក..........36
**ឧបសម្ព័ន្ធទី១**..........40
**គំរូនៃការបង្កើតច្បាប់ថ្មីស្ដីពី ហិរញ្ញវត្ថុឃោសនានយោបាយ**
**ឧបសម្ព័ន្ធទី២**..........43
**វត្តមានអ្នកចូលរួមនៅក្នុងសិក្ខាសាលា ស្ដីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត**
**ឧបសម្ព័ន្ធទី៣**..........45
**ការចុះ និងចាក់ផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយ**

## ១.សេចក្តីផ្តើម

នៅក្នុងប្រទេសដែលប្រកាន់យកលិទ្ធិប្រជាធិបតេយ្យ គេមិនអាចជ្រើសយកនីតិបុគ្គលណាមួយក្រៅពីគណបក្សនយោបាយមកគ្រប់គ្រងប្រទេសបានជាដាច់ខាត។ ទន្ទឹមនិងនេះដែរ ប្រជាធិបតេយ្យនឹងមិនអាចដំណើរការទៅបានត្រឹមត្រូវទេ ប្រសិនបើគ្មានវត្តមានរបស់គណបក្សនយោបាយក្នុងការប្រកួតប្រជែងគ្នា តាមការបោះឆ្នោតដោយសេរី និងយុត្តិធ៌មដើម្បីធ្វើការដឹកនាំប្រទេស។ ដើម្បីចូលរួមក្នុងដំណើរការឃោសនាបោះឆ្នោត ក្នុងការរកសម្លេងឆ្នោតគណបក្សនយោបាយនិមួយៗត្រូវការលុយ ដើម្បីធ្វើការឃោសនានូវគោលនយោបាយរបស់ខ្លួនឲ្យទទួលបានសម្លេងគាំទ្រក្នុងការដឹកនាំប្រទេស។ ដូច្នេះគណបក្សនយោបាយ ត្រូវការមានប្រភពចំណូលមួយដើម្បីទប់ទល់និងការចំណាយពេលឃោសនាបោះឆ្នោត និងបុគ្គលិកដែលបំរើការងារនៅក្នុងអង្គភាពបក្សនោះផងដែរ។

ក្នុងការស្វែងរកនូវមូលនិធិមកទ្រទ្រង់នូវការចំណាយទាំងអស់នេះ គណបក្សនយោបាយខ្លះអាចប្រាសចាកទៅនឹងក្រមសីលធ៌ម ឬប្រព្រឹត្តនូវអំពើទុច្ចរិតផ្សេងៗ ក្នុងស្វែងរកមូលនិធិនេះ។ គណបក្សនយោបាយខ្លះ អាចទទួលយកមូលនិធិ ដែលភ្ជាប់មកជាមួយនូវការសន្យារបស់អ្នកផ្តល់ឲ្យនៅក្រោយពេលដែលគណបក្សនោះបានជាប់ឆ្នោត។ មានគណបក្សខ្លះ ប្រើមូលនិធិរបស់ខ្លួនយកទៅធ្វើអំពើផ្សេងៗ ដែលផ្ទុយពីគោលការណ៍នៃការបោះឆ្នោតដោយសេរី និងយុត្តិធ៌ម ដូចជាការទិញសន្លឹកឆ្នោត ឬសូកប៉ាន់ទៅមន្ត្រីបោះឆ្នោតជាដើម។ ហើយគណបក្សនយោបាយខ្លះ បានគៃបន្លំយកធនធានរបស់រដ្ឋទៅប្រើប្រាស់ជាមធ្យោបាយ ក្នុងការឃោសនាបោះឆ្នោតឲ្យគណបក្សនយោបាយរបស់ខ្លួនក្នុងការរកសម្លេងគាំទ្រ។ អំពើទាំងអស់នេះបានធ្វើឲ្យលទ្ធិប្រជាធិបតេយ្យមានការរង្គោះរង្គើរយ៉ាងខ្លាំង ជាពិសេសជំនឿទុកចិត្តរបស់សាធារណជនមកលើគណបក្សនយោបាយ និងលទ្ធិប្រជាធិបតេយ្យ។

យោងតាមរបាយការណ៍ស្ទង់មតិមួយរបស់ពិភពលោក (World Value Survey 2004-2007) បានឲ្យដឹងថា ប្រជាពលរដ្ឋនៅក្នុងប្រទេសចំនួន៥៤ដែលមានចំនួន៧៣%គ្មានជំនឿទុកចិត្តមកលើគណបក្សនយោបាយទាល់តែសោះ។ មូលហេតុចម្បងបំផុតនៃការអស់ជំនឿពីប្រជាពលរដ្ឋទាំងនោះ គឺការខ្វះនូវតម្លាភាព ថាតើគណបក្សនយោបាយទាំងនោះទទួលបានលុយមកពីប្រភពណាខ្លះ ហើយបានចំណាយលុយយ៉ាងដូចម្តេចខ្លះ ជាពិសេសនៅក្នុងកុំឡុងពេលឃោសនាបោះឆ្នោតដែលជារយៈពេលមួយសំខាន់បំផុត។ បញ្ហានេះជាបញ្ហាយ៉ាងចម្បង ដែលប្រទេសជាច្រើនលើសកលលោកកំពុងប្រឈម និងត្រូវបានអង្គការសហប្រជាជាតិបានយកមកចែងនៅក្នុងសន្ធិសញ្ញា ស្តីពីការ

ប្រឆាំងអំពើពុករលួយ នៅត្រង់ចំណុចទី៣នៃមាត្រា៧ បានអំពាវនាវឲ្យរដ្ឋដែលជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញានេះទាំងអស់លើកកំពស់នូវតម្លាភាព ក្នុងការផ្តល់មូលនិធិហិរញ្ញវត្ថុទៅឲ្យបេក្ខជនដែលឈរឈ្មោះសម្រាប់តំណែងនៅក្នុងមុខងារសាធារណៈ និងការផ្តល់មូលនិធិហិរញ្ញវត្ថុទៅឲ្យគណបក្សនយោបាយផងដែរ។

មកទល់នឹងពេលនេះ មានប្រទេសជាច្រើនលើសកលលោកដែលបាន និងកំពុងផ្លាស់ប្តូររបបនយោបាយ បានឲ្យសច្ចាប័នទៅលើសន្ធិសញ្ញានេះ ហើយយកគោលការណ៍តម្លាភាព និងគណនេយ្យភាពបញ្ចូលទៅច្បាប់ផ្ទៃក្នុងរបស់ខ្លួន ជាពិសេសការផ្តល់មូលនិធិជូនទៅឲ្យគណបក្សនយោបាយ និងបេក្ខជនសម្រាប់មុខតំណែងសាធារណៈ។ ចំណែកប្រទេសខ្លះទៀត ដែលមានក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និងបេក្ខជនរួចហើយ ក៏បានធ្វើការកែប្រែថែមទៀត ដើម្បីឲ្យស្រុបតាមបរិបទសង្គមជាក់ស្តែង និងកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើការដឹកនាំប្រទេសរបស់គណបក្សនយោបាយឲ្យកាន់តែខ្លាំងថែមទៀត។

ប្រទេសកម្ពុជា គួរដល់ពេលវេលាដែលត្រូវមានច្បាប់សម្រាប់គ្រប់គ្រងលើមូលនិធិរបស់គណបក្សនយោបាយ និងការឃោសនាបោះឆ្នោតហើយ។ ទំនាក់ទំនងរវាងនយោបាយ និងថវិកាបានបង្កើតឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងនៅក្នុងចំណោមប្រទេសជាច្រើន ព្រោះបញ្ហាថវិកា និងគណបក្សនយោបាយទាក់ទិនតែមិនត្រឹមតែចំនួនទឹកប្រាក់ដែលពាក់ពន្ធ័ ឬប្រភពនៃមូលនិធិដែលស្ថិតនៅក្រោមមន្ទិលសង្ស័យប៉ុណ្ណោះទេ តែគណបក្សនយោបាយអាចនឹងក្លាយទៅជាឆ្អឹងខ្នងនៃរដ្ឋប្រជាធិបតេយ្យផងដែរ ជាពិសេសកាបោះឆ្នោតប្រកបដោយយុត្តិធ៌មមួយ។ ការតាក់តែងច្បាប់គ្រប់គ្រងមូលនិធិគណបក្សនយោបាយ និងការឃោសនាសំខាន់បំផុត គឺដើម្បីធានា **អប្បរមានៃភាពសមហេតុផល** នៅក្នុងការប្រើប្រាស់ធនធានសាធារណៈ សម្រាប់គោលបំណង និងផលប្រយោជន៍នយោបាយការបោះឆ្នោតសម្រាប់គណបក្សនយោបាយ។ សំខាន់ជាងនេះទៅទៀត ការប្រតិបត្តិការ និងការផ្តល់មូលនិធិនយោបាយ និងអ្នកនយោបាយដែលនាំមកនូវតម្លៃប្រជាធិបតេយ្យសមធ៌ម និងភាពត្រឹមត្រូវហើយ ក៏ជាការដាក់កំរិត ឬជំទាស់រវាងអ្នកនយោបាយដែលទាក់ទិន ពិសេសតម្លាភាព និងកំរិតចំណូល និងចំណាយ ដែលមិនអនុញ្ញាតឲ្យថវិកាមានអំណាចគ្របដណ្តប់លើប្រព័ន្ធប្រជាធិបតេយ្យនោះ។

ជាការពិតណាស់ដែលគណបក្សនយោបាយ គួរតែមានប្រភពច្បាស់លាស់ និងមានតម្លាភាពក្នុងការចាត់ចែងកិច្ចការនយោបាយរបស់ខ្លួន ជាពិសេសទាក់ទងទៅនឹងតម្លាភាព និងការចាត់ចែងធនធានរបស់ខ្លួនមុននឹងឈានជើងចូលទៅចាត់ចែង និងគ្រប់គ្រងធនធាននៅក្នុងរដ្ឋាភិបាល។ រាជ

រដ្ឋាភិបាលកម្ពុជាធ្លាប់លើកឡើងពីជំហរច្បាស់លាស់របស់ខ្លួន ចំពោះសង្គ្រាមប្រឆាំងនឹងអំពើពុករលួយ ប៉ុន្តែការចាត់ចែងឲ្យមាននិយ័តកម្មលើការគ្រប់គ្រងមូលនិធិគណបក្សនយោបាយ គឺជាចំណែកមួយយ៉ាងសំខាន់ ក្នុងការដោះស្រាយភាពចំរូងចំរាស់ និងមន្ទិលសង្ស័យនានារបស់គណបក្សនយោបាយពីអំពើពុករលួយ។

ថ្មីៗនេះ បើតាមការសិក្សារបស់វិទ្យាស្ថានអន្តរជាតិ IDEA លើប្រទេសចំនួន៧៥លើពិភពលោក (ប្រទេសដែលមានការបោះឆ្នោតពហុបក្ស និងដំណើរការប្រជាធិបតេយ្យនូបនីយកម្មចំនួន ១២៣ប្រទេស) ដែលមានច្បាប់សម្រាប់គ្រប់គ្រងទៅលើមូលនិធិរបស់គណបក្សនយោបាយ និងថវិកាក្នុងការឃោសនាបោះឆ្នោត ឬតាមរយៈច្បាប់បោះឆ្នោត ឬច្បាប់គណបក្សនយោបាយ។ នៅប្រទេសប្រជាធិបតេយ្យមួយចំនួន ដូចជាប្រទេសឥណ្ឌា និងបង់ក្លាដេសច្បាប់ស្តីពីការគ្រប់គ្រងមូលនិធិនយោបាយ គឺផ្តោតលើបុគ្គលម្នាក់ៗនៃបេក្ខជនក្នុងពេលឃោសនាបោះឆ្នោត។ នៅប្រទេសបង់ក្លាដេស បេក្ខជននៃគណបក្សនយោបាយមួយ ដែលធ្វើការប្រកួតប្រជែងនៅក្នុងមណ្ឌលមួយមិនឲ្យចំណាយថវិកាលើសពី២ម៉ឺនដុល្លារទេ។ នៅប្រទេសឥណ្ឌូនេស៊ី ច្បាប់បោះឆ្នោតឆ្នាំ២០០៨បានដាក់បញ្ចូលបញ្ហាដែលទាក់ទិននិងបញ្ហាឃោសនា ដែលបង្ខំគណបក្សនយោបាយ ត្រូវតែផ្តល់របាយការណ៍អំពីចំណូល និងចំណាយ។

ប្រទេសនានានៅក្នុងទ្វីបអាស៊ីជាច្រើនបានងាកមករក និងធ្វើការចាប់អារម្មណ៍បង្កើតឲ្យមានមូលនិធិសាធារណៈសម្រាប់គណបក្សនយោបាយ ដូចជានៅប្រទេសស្រីល័ង្ការជាដើម។ ចំណែកនៅអាស៊ីអាគ្នេយ៍វិញ ច្បាប់ទាំងនោះយើងឃើញមានការផ្តួចផ្តើមឲ្យមាននៅក្នុងប្រទេសថៃ។ ប្រទេសទាំងនោះ ធ្លាប់មានពិសោធន៍ជាក់ស្តែងលើច្បាប់មូលនិធិគណបក្សនយោបាយ និងការគ្រប់គ្រង ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នៃអំពើពុករលួយនៅក្នុងវិស័យនយោបាយ។ មានការតស៊ូមតិយ៉ាងខ្លាំងនៅប្រទេសថៃ ដើម្បីលុបបំបាត់ការទិញសន្លឹកឆ្នោតដែលគណបក្សនយោបាយ និងអ្នកនយោបាយបានយកលុយទៅទិញទឹកចិត្តអ្នកបោះឆ្នោតក្នុងកំឡុងពេលបោះឆ្នោត។

ចំពោះប្រទេសកម្ពុជា មតិរបស់គណបក្សជំទាស់មួយចំនួនបានលើកឡើងពីទ្វេគ្រោះនៃការបង្កើតឲ្យមាននិយ័តកម្មនេះ ជាធម្មតា ច្បាប់នេះតម្រូវឲ្យគណបក្សនយោបាយធ្វើសេចក្តីរាយការណ៍ពីចំណូល និងចំណាយរបស់ខ្លួន ជាពិសេសប្រភពចំណូលគួរមានភាពច្បាស់លាស់ចំណុចនេះ ហើយដែលក្រុមបក្សជំទាស់លើកឡើងថា ខ្លួនអាចបាត់បងចំណូលមួយចំនួនដោយសារអ្នកឧបត្ថម្ភថវិកាមានការខ្លាចរអាក្នុងការបញ្ចេញឲ្យដឹងជាសាធារណៈនូវឈ្មោះរបស់ពួកគេ។ ចំណែកឯឥស្សរជន និងមន្ត្រីនយោបាយគណបក្សកាន់អំណាច ក៏បានលើកឡើងអំពីបញ្ហាសន្តិសុខនៅពេល

ដែលពួកគេបើកចំហព័ត៌មានអំពីទ្រព្យសម្បត្តរបស់ពួកគេ ដែលទាក់ទិននិងច្បាប់ប្រឆាំងអំពើពុករលួយ។

ឆន្ទៈ និងការលះបង់របស់អ្នកនយោបាយដើម្បីប្រយោជន៍ជាតិ គឺពិតជាចាំបាច់ក្នុងការរៀបចំច្បាប់ប្រឆាំងអំពើពុករលួយ រួមជាមួយច្បាប់គ្រប់គ្រងមូលនិធិគណបក្សនយោបាយ និងការឃោសនាបោះឆ្នោត។ អំពើពុករលួយចេះតែកើនឡើងៗ ធ្វើឲ្យអាប់ខ្មួចរូបភាពសាធារណៈរបស់គណបក្សភាគច្រើន និងអ្នកនយោបាយជាប់ឆ្នោត បើមិនខំទប់ស្កាត់បញ្ហានេះទេ យូរទៅអំពើពុករលួយនិងនយោបាយអាចបង្កើតអោយមានបញ្ហាអសន្តិសុខអស្ថេរភាព និងបញ្ហាសង្គមធ្ងន់ធ្ងរជាមិនខាន។

## ២.អនុសាសន៍របស់ខុមហ្វ្រែល

នៅក្នុងសិក្ខាសាលា ក្រុមការងារច្បាប់នៃគណៈកម្មាធិការខុមហ្វ្រែល បានបង្ហាញជម្រើសចំនួនបី ដែលជាលទ្ធភាពក្នុងការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត។ ជម្រើសទាំងនោះមានដូចតទៅ៖

### 1.ធ្វើច្បាប់ថ្មី ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត

នៅក្នុងការធ្វើច្បាប់ថ្មីនេះ នឹងមានបទបញ្ញត្តិដែលតម្រូវឲ្យគណបក្ស និងបេក្ខជនចុះបញ្ជីនូវទ្រព្យសម្បត្តិ ចំណូល និងចំណាយ បំណុលទាំងអស់ និងអំណោយដែលទទួលបាន សម្រាប់ដំណើរការរបស់គណបក្សពេលឃោសនាបោះឆ្នោត ហើយចេញផ្សាយនូវរ បាយការណ៍ទាំងនោះតាមរយៈពេលកំណត់ជាទៀងទាត់មួយ ហើយដាក់របាយការណ៍នោះជូនទៅស្ថាប័នមួយ ដែលត្រូវបានបង្កើតឡើងដោយឯករាជ្យពីរដ្ឋាភិបាល ទាំងការ ចាត់តាំង និងថវិកា នៃស្ថាប័ននោះដើម្បីពិនិត្យមើល ស៊ើបអង្កេត និងតាមដានការគោរពច្បាប់របស់គណបក្ស និងបេក្ខជន។ ម៉្យាងវិញទៀត ដើម្បីធានា ឲ្យមានយុត្តិធម៌ក្នុងការប្រកួតប្រជែងរវាងគណបក្សដែលសម្បូរធនធាន និង គណបក្សដែលមិនសូវមានធនធាន គឺធ្វើការកំណត់នូវការចំណាយរបស់គណបក្សសម្រាប់ពេលបោះឆ្នោតម្តងៗ។ នៅក្នុងនោះ រដ្ឋក៍មានកាតព្វកិច្ចក្នុងការជួយមកគណបក្សនយោបាយផងដែរ ដោ យផ្តល់មកជាមូលនិធិសាធារណៈដើម្បីលើកទឹកចិត្តឲ្យគណបក្ស និងបេក្ខជនគោរពតាមច្បាប់ និងបទដ្ឋាននានា និងធានានូវអត្ថិភាពរបស់គណបក្សក្នុងលទ្ធិប្រជាធិបតេយ្យ។ (ពិនិត្យលំអិតនៃគំរូច្បាប់នៅក្នុងឧបសម្ព័ន្ធ១)

### 2. វិសោធនកម្ម ស្តីពីហិរញ្ញវត្ថុសំរាប់ការឃោសនានៅក្នុងច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬក្រុមប្រឹក្សាឃុំ-សង្កាត់

ខាងក្រោមនេះ គឺជាគំរូនៃការស្នើ វិសោធនកម្មទៅលើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅកម្ពុជាឆ្នាំ២០០៨ ដែលមានលទ្ធភាពពិភាក្សាកែលំអ និងបន្ថែមជំពូកទី៧ស្តីពី

ការឃោសនាបោះឆ្នោត និងជំពូកទាក់ទងពីការកំណត់ទណ្ឌកម្ម។

## ជំពូកទី ៧ ការឃោសនាបោះឆ្នោត

**មាត្រា៨១:**

ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយឬបេក្ខជនផ្ទាល់។ រដ្ឋអាចផ្តល់ថវិកាជាតិស្មើៗគ្នា ដល់គ្រប់គណបក្សនយោបាយសម្រាប់ប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

**មាត្រា៨២:**

គ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានគណនីពិសេសមួយដែលបើកនៅធនាគារក្នុងប្រទេស ។

គណនីពិសេសនេះ ត្រូវកាន់កាប់ដោយហិរញ្ញឹករបស់គណបក្សនយោបាយ ដែលត្រូវជ្រើសតាំង តាមនីតិវិធីនៃវិធានផ្ទៃក្នុងរបស់គណបក្សនយោបាយនោះ និងបានជូនដំណឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិច៧ថ្ងៃមុនចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត។

**មាត្រា៨៣:**

វិភាគទានទាំងអស់ដែលគណបក្សនយោបាយបានទទួល ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនា ត្រូវតែចេញពីគណនីពិសេសនេះ។

## ការបន្ថែមមាត្រានៅក្នុងជំពូកទី៧

**មាត្រា៨៤: ថ្មី**

ហេរញ្ញឹករបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវធ្វើរបាយការណ៍គណនេយ្យបឋមមួយ ដែលបញ្ជាក់ពីគម្រោងថវិកាដំបូង និងព័ត៌មានទាក់ទងនឹងគណនីពិសេសសំរាប់ការឃោសនាបោះឆ្នោត ប្រគល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងយូរ៧ថ្ងៃ ក្រោយពេលចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត។

នីតិវិធីនៃការធ្វើរបាយការណ៍គណនេយ្យបឋមនេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា៨៥: ថ្មី**

ហេរញ្ញឹករបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយត្រូវចេញ

បង្កាន់ដៃទទួលអំណោយ នៅរាល់ពេលទទួលអំណោយជាប្រាក់ ឬសម្ភារៈ ដែលមានតំលៃស្មើនឹង ឬច្រើនជាង មួយលាន(១ ០០០០០០) រៀល ពីគ្រប់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានអនុញ្ញាត ដែលត្រូវបានអនុញ្ញាត តាមច្បាប់ ស្តីគណបក្សនយោបាយ ។

ទម្រង់បង្កាន់ដៃទទួលប្រាក់ និងព័ត៌មានចាំបាច់ ដែលត្រូវសរសេរក្នុងបង្កាន់ដៃត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា៨៦:ថ្មី**

ហេរញ្ញិករបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវធ្វើរាយការណ៍ពីការទទួលអំណោយនេះ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលមិនលើសពីមួយសប្តាហ៍បន្ទាប់ពីបានទទួលអំណោយ។

**មាត្រា៨៧: ថ្មី**

កម្រិតថវិកាចំណាយលើការឃោសនាបោះឆ្នោតទូទាំងប្រទេស សម្រាប់គណបក្សនយោបាយនីមួយៗ ឬបញ្ជីបេក្ខជនឈរឈ្មោះក្នុងមណ្ឌលត្រូវគណនាតាមរូបមន្តដូចខាងក្រោមនេះ៖

ចំនួនប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបោះឆ្នោតសរុបក្នុងមណ្ឌល គុណនឹង មេគុណបួនពាន់(៤០០០)រៀល។

**មាត្រា៨៨: ថ្មី**

ហេរញ្ញិកគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវធ្វើរបាយការណ៍គណនេយ្យចុងក្រោយមួយ ដែលរាយនាមប្រភពចំណូល និងការចំណាយទាំងអស់ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រគល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរបំផុតត្រឹមថ្ងៃបិទយុទ្ធនាការបោះឆ្នោត។

នីតិវិធីនៃការធ្វើរបាយការណ៍គណនេយ្យចុងក្រោយនេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា៨៩: ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការប្រកាសផ្សាយជាសាធារណៈតាមប្រព័ន្ធឃោសនាជាតិ និងឯកជនសមស្របនូវរបាយការណ៍ហិរញ្ញវត្ថុបឋម និងចុងក្រោយរបស់គណបក្សនយោបាយទាំងឡាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ មិនត្រូវធ្វើហួសថ្ងៃបោះឆ្នោតឡើយ។

**មាត្រា៩០: ថ្មី**

ការប្រកាសផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុនេះ មិនត្រូវបានប្រកាសនូវឈ្មោះរបស់អ្នកធ្វើអំណោយឡើយ វៀរលែងតែមានការស្នើសុំពីបេក្ខជន ឬគណបក្សនយោបាយដែលបានបញ្ជាក់ពីការយល់ស្របពីអ្នកធ្វើអំណោយ។

## ការកំណត់ពីទណ្ឌកម្ម

**មាត្រា១៣៨: ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយសែន (១០០ ០០០)រៀល ដល់មួយលាន (១០០០០០០)រៀល ហិរញ្ញិកគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយណាដែលមិនបានប្រគល់ ឬប្រគល់មិនទាន់ពេលតាមការកំណត់នៃច្បាប់នេះ នូវរបាយការណ៍ហិរញ្ញវត្ថុគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៣៩: ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយសែន (១០០ ០០០)រៀល ដល់មួយលាន (១ ០០០ ០០០) រៀល ហេរញ្ញឹកគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយណាដែលមិនគោរពតាមបទបញ្ញត្តិ នៃមាត្រាបន្ថែម (ស្តីពីកាតព្វកិច្ចធ្វើបង្កាន់ដៃ)។

**មាត្រា១៤០: ថ្មី**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់ពីរ(២)ឆ្នាំ ហើយពិន័យជាប្រាក់ពីមួយលាន (១ ០០០ ០០០)រៀល ដល់ដប់លាន (១០ ០០០ ០០០)រៀល ដោយមិនរាប់បញ្ចូល ពីបទល្មើសព្រហ្មទណ្ឌដ៏ទៃទៀត ហេរញ្ញឹកគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយណា ដែលធ្វើរបាយការណ៍ មិនសមស្របតាមស្ថានភាពជាក់ស្តែង ក្រោយពីបើកការស៊ើបអង្កេតដោយ តុលាការតាមបណ្តឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១៤១: ថ្មី**

ប្រសិនបើ បទល្មើសដូចមានចែងក្នុងមាត្រាបន្ថែម (មុន) ត្រូវបានប្រព្រឹត្តក្រោមការបញ្ជាពីបេក្ខជន ឬគណបក្សនយោបាយដែលបានបញ្ជា ត្រូវផ្តន្ទាទោសទ្វេដង។

### 3. វិសោធនកម្មលើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០០៧

ខាងក្រោមនេះ គឺជាគំរូវិសោធនកម្មលើបទបញ្ជា និងនីតិវិធីសម្រាប់បោះឆ្នោតជ្រើសតាំង

តំណាងរាស្រ្តនៅកម្ពុជាឆ្នាំ២០០៨។ លទ្ធភាពវិសោធនកម្មពិភាក្សា កែលំអ និងបន្ថែមប្រការមួយចំនួនទៅក្នុងជំពូកទី៧ ដែលអាចពង្រឹងសិទ្ធិរបស់ គ.ជ.ប. ក្នុងការត្រួតពិនិត្យចំណូល និងចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ។

## បទបញ្ញត្តិបន្ថែមលើជំពូកទី៧ ការឃោសនាបោះឆ្នោត

**ប្រការ ៧.២៥:**

អនុលោមតាមមាត្រា១៦ថ្មី នៃច្បាប់ស្ដីពីស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចត្រួតពិនិត្យចំណូល និងចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ។

**៧.២៥.១:** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអំណាចក្នុងការផ្ដួចផ្ដើមកិច្ចត្រួតពិនិត្យឡើងវិញជាផ្លូវការណាមួយ លើរបាយការចំណូល និងចំណាយរបស់គណបក្ស នយោបាយ។

**៧.២៥.២:** ការចាត់ចែងផ្សព្វផ្សាយ និងត្រួតពិនិត្យរបាយការណ៍ចំណូល និងចំណាយរបស់គណបក្សនយោបាយពេលឃោសនាបោះឆ្នោត ជាកាទទួលខុសត្រូវរបស់នាយកដ្ឋាន ប្រតិបត្តិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**៧.២៥.៣:** នាយកដ្ឋានប្រតិបត្តិការ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ នូវរបាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយទាំងនោះ ចាប់ពីពេលចាប់ផ្ដើមយុទ្ធនាការ ឃោសនាបោះឆ្នោត និងនៅក្រោយពេលឃោសនាបោះឆ្នោត។

**៧.២៥.៤:** នាយកដ្ឋានប្រតិបត្តិការ ជាអ្នកធានាថាគ្រប់គណបក្សនយោបាយបានយល់ដឹងពីការប្រកាសព័ត៌មានរបាយការណ៍ចំណូល និងចំណាយក្នុងពេលឃោសនាបោះឆ្នោត និងចូលរួមអនុវត្តតាមបទបញ្ញត្តិដែលមានស្រាប់ តាមរយៈការដឹកនាបណ្ដុះបណ្ដាល ស្ដីពីការគ្រប់គ្រងរបាយការណ៍ ការរាយការណ៍ និងគណនេយ្យភាពគណបក្សនយោបាយ។

**ប្រការ ៧.២៦:**

គណបក្សនយោបាយដែលបានចុះឈ្មោះ ត្រូវតែបំពេញរបាយការណ៍ចំណូល និងចំណាយក្នុងពេលឃោសនាបឋម ផ្ញើ មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរ១០ថ្ងៃ[1]មុនថ្ងៃកំណត់ធ្វើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ។

**៧.២៦.១:** គណបក្សនយោបាយត្រូវបញ្ជូនរបាយការណ៍ពីចំណូល និងចំណាយពេលឃោសនាសរុបចុងក្រោយ មក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងយូរបំផុត៣០ថ្ងៃក្រោយពេលប្រកាសលទ្ធផលនៃការបោះឆ្នោត។

---

[1] តាមការណែនាំអំពីមូលនិធិអន្តរជាតិដើម្បីប្រព័ន្ធបោះឆ្នោត(International Foundation for Elections: IFES)

**៧.២៦.២:** បន្ទាប់ពីបានទទួលរបាយការណ៍ចំណូល និងចំណាយក្នុងពេលឃោសនាបោះពីគណបក្សនយោបាយ នាយកដ្ឋានប្រតិបត្តិការ ត្រូវប្រកាសព័ត៌មានជាបន្ទាន់នូវរបាយការណ៍ចំណូល និងចំណាយរបស់គណបក្សនយោបាយ នៅលើគេហទំព័រផ្លូវការរបស់ខ្លួន និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

**៧.២៦.៣:** ប្រសិនបើ គណបក្សនយោបាយណាមួយ ខកខានមិនបានបញ្ជូនរបាយការណ៍ចំណូល និងចំណាយក្នុងពេលឃោសនាមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមកាលកំណត់ ដោយមិនមានមូលហេតុត្រឹមត្រូវទេ នាយកដ្ឋានប្រតិបត្តិការ មានសិទ្ធិធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីដំណើរខកខានមួយនេះ។

**៧.២៦.៤:** ការបញ្ជូនរបាយការណ៍ចំណូល និងចំណាយពេល ឃោសនាបោះឆ្នោតអាចនឹងពន្យារពេលយ៉ាងយូរ៥ថ្ងៃ ក្នុងករណីប្រធានសក្តិ ឬកាលៈទេសៈអសន្តិសុខ។

**៧.២៦.៥:** ការស្នើសុំពន្យារពេល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់ និងត្រឹមត្រូវ។

**ប្រការ ៧.២៧:**

អនុលោមតាមមាត្រា ៧៤នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការរៀបចំការបោះឆ្នោត ត្រូវស្នើដល់គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសាព័ត៌មាន វិទ្យុ និងទូរទស្សន៍របស់រដ្ឋ ដើម្បីចុះផ្សាយគ្រប់ព័ត៌មាន ដែលផ្សព្វផ្សាយពីការងារបោះឆ្នោតដើម្បីអប់រំដល់អ្នកបោះឆ្នោត និងគណបក្សនយោបាយដោយមិនយកថ្លៃ។

**៧.២៧.១:** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រើប្រាស់អំណាចនេះសម្រាប់គ្រប់គ្រងការរៀបចំ និងត្រួតពិនត្យរបាយការណ៍ចំណូល និងចំណាយរបស់គណបក្សនយោ បាយពេលឃោសនាបោះឆ្នោត ដោយស្នើដល់ប្រព័ន្ធផ្សព្វផ្សាយបញ្ជូនរបាយការណ៍ចំណា យលើថ្លៃជាវសេវាផ្សព្វផ្សាយរបស់គណបក្សនយោបាយដែលពាក់ព័ន្ធ។

**៧.២៧.២:** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលខុសត្រូវការអង្កេតស្រាវជ្រាវ និងត្រួតពិនិត្យរបាយការណ៍ចំណូល និងចំណាយពេលឃោសនាបោះឆ្នោតរបស់ គណបក្សនយោបាយដែលបានចុះឈ្មោះ និងបេក្ខជនឈរឈ្មោះក្រោយពេលបោះឆ្នោត។

## ៣. របាយការណ៍សង្ខេបក្នុងសិក្ខាសាលា ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយ ពេលឃោសនាបោះឆ្នោត

ខុមហ្វ្រែលបានធ្វើសិក្ខាសាលា ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត នៅថ្ងៃទី២៦ខែឧសភាឆ្នាំ២០១០នៅសណ្ឋាគារអីមភីរៀលហ្គាដិនអូតែលភ្នំពេញ។ នៅក្នុងសិក្ខាសាលានោះមានអ្នកចូលរួមចំនួន៥០នាក់ ដែលនៅក្នុងនោះមានអ្នកតំណាងរាស្ត្រចំនួន៥រូបមកពីគ្រប់គណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា តំណាងមកពីគណៈកម្មាធិការជាតិរៀប ចំការបោះឆ្នោត ១រូប តំណាងស្ថានទូត បារាំង៣រូប ព្រមទាំងអ្នកតំណាងឲ្យអង្គការក្រៅរដ្ឋាភិបាលនានា និងអ្នកសារព័ត៌មាន។

វាគ្មិននៅក្នុងសិក្ខាសាលានោះរួមមាន លោក ធន សារាយ ឯកឧត្តម ជាម យៀប ឯកឧត្តម សុន ឆ័យ ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ ឯកឧត្តម សៅ រ៉ានី ឯកឧត្តម ទេព ននី្ទ លោក សុក លៈ ទីប៉ោ Mr.Dominique MAS, Mr. Robert A. Patterson និងលោក គល់ បញ្ញា។

លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានសមាគមអាដហុកបានផ្តល់យោបល់ថា នេះជាជំហ៊ានដ៏មានសារៈសំខាន់ដែលគណៈកម្មាធិការខុមហ្វ្រែលបានរៀបចំឡើង ដើម្បីឲ្យមានតម្លាភាពនៅក្នុងការឃោសនាបោះឆ្នោត ហើយការចូលរួមរបស់តំណាងគណបក្សនយោបាយនៅក្នុងកិច្ចពិភាក្សានៅពេលនេះ គឺជាដំណើរការលទ្ធិប្រជាធិបតេយ្យមួយដ៏ល្អ។ ដោយសារប្រទេសកម្ពុជានៅមិនទាន់មានច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយពេលបោះឆ្នោតឲ្យមានតម្លាភាពសមធ៌ម និងយុត្តិធ៌មនៅពេលឃោសនា។

ការជួបជុំដើម្បីពិភាក្សាគ្នា គឺជាដំណើរការដ៏ល្អមួយដែលយើងអាចជជែកគ្នា ពីព្រោះជួនកាលការចង់បានខ្ពស់ពេកមិនអាចធ្វើឲ្យប្រព្រឹត្តទៅរួច។

ឯកឧត្តម **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភាមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សមួយដ៏មានវ័យចំណាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបច្ចុប្បន្នកំពុងកាន់អំណាចបានរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កំពូល ហើយជាគណបក្សមួយដែលបានដឹកនាំប្រទេស ចាប់តាំងពីបាតដៃទទេរហូតមកដល់ថ្ងៃនេះ ហើយវាមិនមែនជារឿងងាយស្រួលទេ ពីព្រោះនៅក្នុងរបបប្រល័យពូជសាសន៍គេបានបំផ្លាញខ្ទេចខ្ទីនូវហេដ្ឋារចនាសម្ព័ន្ធទាំងឡាយរាបដល់ដី។ គណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាចមានលទ្ធភាពគ្រប់គ្រាន់ជាងគណបក្សដ៏ទៃ ដោយសារតែគណបក្សនេះមានសមាជិកច្រើនរហូតជាង៥លាននាក់។ ជាមួយនោះក៏មានអាជីវកម្ម និងអចលនវត្ថុជាច្រើន

ទៀតដែលអាចផ្ដល់មូលនិធិគាំទ្រគណបក្ស។ ក្នុងនាមជាគណបក្សមួយដែលកំពុងកាន់អំណាច ឯកឧត្តមគាំទ្រឲ្យមានច្បាប់ ស្ដីពីកាគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយពេលបោះឆ្នោត នេះ ពីព្រោះច្បាប់មិនមែនសម្រាប់គណបក្សណាមួយទេ។ ឯកឧត្តមក៏បានលើកពីការផ្ដល់ហិរញ្ញវត្ថុពីរដ្ឋទៅឲ្យគណបក្សនយោបាយដោយផ្អែកទៅលើមាត្រា២៨នៃច្បាប់ ស្ដីពីគណបក្សនយោបាយ ដែលបានចែងថា រដ្ឋអាចផ្ដល់ថវិកាជាតិស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយសម្រាប់ប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គណបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣%នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអសនៈមួយក្នុងសភា គណបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញ ក្នុងរយៈពេល៣ខែយ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរនៃការបោះឆ្នោត។

ឯកឧត្តមបានលើកឡើងថាអ្នកតំណាងរាស្ត្រក៏ដូចជាអង្គការសង្គមស៊ីវិលផ្សេងៗ គួរដាក់សំណើរជូនរដ្ឋសភាដើម្បីធ្វើការពិចារណាទៅលើលទ្ធភាពនៃការអនុវត្តន៍នូវមាត្រានេះ (មាត្រា២៨នៃច្បាប់ស្ដីពីគណបក្សនយោបាយ)។

ឯកឧត្តម **សុន ឆ័យ** មកពីគណបក្សសមរង្ស៊ីលើកឡើងថា គណបក្សសមរង្ស៊ីគាំទ្រឲ្យមានច្បាប់ ស្ដីពីការគ្រប់គ្រងមូលនិធិគណបក្សនយោបាយ ដើម្បីធ្វើឲ្យការឃោសនាប្រព្រឹត្តទៅដោយស្មើភាពពីព្រោះថា លុយមានឥទ្ធិពលជាទីបំផុតដែលគេអាចយកទៅប្រើប្រាស់នៅក្នុងពេលឃោសនាបោះឆ្នោត ហើយប្រព្រឹត្តអំពើផ្សេងៗខុសពីច្បាប់ដែលបានកំណត់ ឬអាចឈានទៅដល់ការទិញសន្លឹកឆ្នោតផងដែរ។ ឯកឧត្តមក៏បានលើកឡើងពីការព្រួយបារម្ភផ្សេងទៀត ដែលជាករណីកើតមាននៅក្នុងប្រទេសមួយចំនួនដោយរាប់ទាំងកម្ពុជាផង លើកិច្ចការបោះឆ្នោត គឺគ្មានវិធានការគ្រប់គ្រងលើជំនួយហិរញ្ញវត្ថុ ដែលគណបក្សនយោបាយតែងទទួលបានពីក្រុមហ៊ុន និងក្រុមមនុស្សមួយចំនួនសម្រាប់គេប្រើប្រាស់លើការងារបោះឆ្នោត ហើយមានករណីខ្លះសម្រាប់ការទិញដូរសន្លឹកឆ្នោតផង។ ឯកឧត្តមបានបន្តទៀតថា ជំនួយហិរញ្ញវត្ថុឬការផ្ដល់លុយកាក់ និងមធ្យោបាយផ្សេងៗនេះ អាចជាភាពមិនយុត្តិធំមសម្រាប់គណបក្សតូច ដែលមានការទាក់ទាញដល់ការផ្ដល់ជំនួយតិចតួច ហើយនាំដល់ការពុំមានធនធានគ្រប់គ្រាន់ ប្រៀបធៀបនឹងគណបក្សធំដែលកាន់អំណាចក្នុងការប្រកួតប្រជែងដោយស្មើភាព ហើយការផ្ដល់ថវិកាជាអំណោយដល់គណបក្ស ដោយគ្មានការគ្រប់គ្រង នេះអាចនាំទៅដល់ការបង្កើតនូវឥទ្ធិពលលើគណបក្សឈ្នះឆ្នោត ដែលត្រូវផ្ដល់ជាផលប្រយោជន៍ផ្នែកជំនួញ ឬអំណាចជាផលប្រយោជន៍ដល់ក្រុមអ្នកផ្ដល់ជំនួយថវិកាវិញ ហើយការណ៍នេះ នាំដល់ការអូសទាញនយោបាយរបស់រដ្ឋាភិបាល និងសេចក្ដីសម្រេចនានារបស់គេចាកចេញពី

ការទទួលខុសត្រូវក្នុងការបម្រើប្រទេសជាតិនោះ។ នៅក្នុងចំណុចនេះមានប្រទេសជាច្រើនបានអនុម័តច្បាប់ ស្តីពីការគ្រប់គ្រងថវិកាសម្រាប់ការឃោសនាបោះឆ្នោត ហើយបានជួយដោះស្រាយដល់បញ្ហាដូចបានលើកឡើងខាងលើនេះ។

ឯកឧត្តមក៏បានលើកយកករណីប្រទេសអាមេរិក និងអូស្ត្រាលីមកធ្វើការបង្ហាញអំពីយន្តការនៃការអនុវត្តន៍នៃច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយនៅក្នុងពេលឃោសនាបោះឆ្នោត ជាពិសេសការផ្តល់មូលនិធិជួយទៅគណបក្សពីរដ្ឋ។ ឯកឧត្តមក៏បានផ្តល់អនុសាសន៍ថាកម្ពុជាអាចយកការអនុវត្តន៍តាមប្រទេសអូស្ត្រាលី ដោយមានការកំរិតតាមបរិបទជាក់ស្តែងនៃប្រទេសកម្ពុជាដោយសារជីវភាពរស់នៅខុសគ្នា ហើយជំរុញឲ្យប្រព័ន្ធឃោសនានានា មានទូរទស្សន៍ និងវិទ្យុជាដើម ផ្តល់លទ្ធភាពឲ្យគណបក្សធ្វើការផ្សព្វផ្សាយគោលនយោបាយរបស់គេ ប្រកបដោយសមធ៌មផងនោះ អាចជាដំណោះស្រាយបានល្អមួយដែរ។ ឯកឧត្តមបានស្នើឲ្យប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិធ្វើការឃោសនាឲ្យបានស្មើភាពគ្នា ជៀសវាងភាពលំអៀង។

ឯកឧត្តម **យ៉ែម បុញ្ញឫទ្ធិ** មកពីគណបក្សសិទ្ធិមនុស្សបានលើកឡើងថា សិក្ខាសាលានេះពិតជាមានសារៈសំខាន់បំផុតចំពោះ ការចំណាយទៅលើការឃោសនាបោះឆ្នោត គួរឲ្យមានភាពស្មើគ្នា ឯកឧត្តមបានបន្តទៀតថា រាល់ការបោះឆ្នោតទាំងអស់លើកលែងតែការបោះឆ្នោតដែលរៀបចំដោយ UNTACចេញ គឺការចំណាយជាបន្ទុករបស់គណបក្សនយោបាយដែលបានចូលរួមទោះបីជាមានច្បាប់ចែងថា រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយសម្រាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក៏ដោយក៏គ្មានគណបក្សណាបានទទួលថវិកាពីរដ្ឋឡើយ។ ឯកឧត្តមក៏បានស្នើ ឲ្យពិនិត្យការធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយ ច្បាប់បោះឆ្នោត និងនីតិវិធីនានា រួមទាំងបទបញ្ជាផ្ទៃក្នុងផងនោះ គឺដើម្បីឲ្យច្បាប់ ឬបទដ្ឋានទាំងនោះបំរើឲ្យការបោះឆ្នោតដោយសេរីត្រឹមត្រូវ យុត្តិធ៌ម និងតម្លាភាព។ បើមានច្បាប់ថ្មីមួយស្តីពីហិរញ្ញវត្ថុ និងអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ សម្រាប់ធ្វើការពិនិត្យចំណូល និងចំណាយរបស់គណបក្សនយោបាយនៅពេលឃោសនា ត្រូវគ្របដណ្តប់ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុម ប្រឹក្សាឃុំសង្កាត់ ព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ។ កំណត់ពីចំនួនអំណោយដែលទទួលបាន និងកំណត់ចំនួនចំណាយ ជាអតិប្បរមាក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។ ចំណែកឯអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុគណបក្សនយោបាយ ត្រូវតែមានសមាសភាពឯករាជ្យ អព្យាក្រិត មានស្វ័យភាពថវិកា គឺជាអង្គភាពមួយដែលមិនស្ថិតនៅក្រោមការគ្រប់គ្រង ឬចាត់ចែងរបស់រាជរដ្ឋាភិបាល។ ឯកឧត្តមបានស្នើឲ្យប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋផ្សព្វផ្សាយព័ត៌មានដោយឯករាជ្យ និងស្មើភាពគ្នាផងដែរ។

ឯកឧត្តម **សៅ រ៉ានី** មកពីគណបក្សជាតិនិយមបានមានប្រសាសន៍ថា ការបង្កើតឲ្យមានច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការឃោសនាបោះឆ្នោត ពិតជាមានសារៈសំខាន់ដែលអាចជួយ ឲ្យគណបក្សដែលមិនមានហិរញ្ញវត្ថុគ្រប់គ្រាន់ មានលទ្ធភាពផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួន ទៅឲ្យប្រជាពលរដ្ឋបានដឹង ហើយច្បាប់នេះនឹងជុំរុញឲ្យមានតម្លាភាពលើគណនេយ្យភាពរបស់ គណបក្សនយោបាយនិមួយៗក្នុងពេលឃោសនាបោះឆ្នោត។

ឯកឧត្តមក៏បានលើកឡើងពីការផ្តល់លុយពីរដ្ឋ ក្នុងការជួយមកគណបក្សនយោបាយនៅក្នុង ពេលឃោសនាបោះឆ្នោត ដែលមានចែងនៅក្នុងច្បាប់ ស្តីពីគណបក្សនយោបាយ មាត្រា ២៨ ដែល បានកំណត់ពីការជួយរបស់រដ្ឋមកគណបក្សនយោបាយពេលឃោសនាបោះឆ្នោត។ ក៏ប៉ុន្តែមកទល់ ពេលនេះ មាត្រា២៨នេះ មិនទាន់ត្រូវបានគេយកមកតាមអនុវត្តនៅឡើយទេ។

ឯកឧត្តម **ទេព នន្ទរី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងមកពីគណបក្ស ហ្វ៊ុនស៊ិនប៉ិច បានធ្វើការគាំទ្រចំពោះគោលបំណងចង់ឲ្យមានច្បាប់ ស្តីពីការគ្រប់គ្រងមូលនិធិ គណបក្សនយោបាយ ពីព្រោះបញ្ហាហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោតជារឿងមួយសំខាន់ ដូច្នេះចាំបាច់ ត្រូវតែមានច្បាប់មួយគ្រប់គ្រង។ ឯកឧត្តមបានមានប្រសាសន៍បន្តថា ជំហររបស់គណបក្សហ្វ៊ុនស៊ិន ប៉ិច គឺចង់បង្កើតឲ្យមានយន្តការត្រួតពិនិត្យដោយឯករាជ្យមួយ ទៅលើហិរញ្ញវត្ថុរបស់គណបក្ស នយោបាយនិមួយៗ ក្នុងកុំឡុងពេលឃោសនាបោះឆ្នោត ដើម្បីទប់ស្កាត់នូវការប្រើប្រាស់ឥទ្ធិពល របស់ទឹកប្រាក់ ដើម្បីទិញឋានៈ តួនាទី និងអំណាច ហើយចំណូល និងចំណាយរបស់គណបក្ស នយោបាយនិមួយៗ ត្រូវតែមានសមធ៌ម និងតម្លាភាព។ បច្ចុប្បន្ននេះមានការចំណាយខុសខ្វង់ជា ច្រើនដែលធ្វើឲ្យខ្វះតម្លាភាព។

លោក Dominique MAS តំណាងមកពីស្ថានទូតបារាំងប្រចាំនៅប្រទេសកម្ពុជា បានធ្វើ បទបង្ហាញពីបទពិសោធន៍របស់ប្រទេសបារាំង ចំពោះក្របខ័ណ្ឌច្បាប់ ស្តីពីហិរញ្ញប្បទានសម្រាប់ យុទ្ធនាការឃោសនាបោះឆ្នោតដែលគ្រប់គ្រងដោយបញ្ញត្តិ ស្តីពីចំណូល និងចំណាយរបស់ គណបក្សនយោបាយ និងបញ្ញត្តិ ស្តីពីចំណូល និងចំណាយសម្រាប់យុទ្ធនាការឃោសនាបោះ ឆ្នោត។ លោកបានបង្ហាញពីគោលបំណងនៃបទប្បញ្ញត្តិទាំងនោះ ដើម្បីឲ្យមានតម្លាភាពនៃការប្រើ ប្រាស់លុយនៅក្នុងឆាកនយោបាយ ហើយគោលការណ៍នៃបទប្បញ្ញត្តិទាំងនោះ គឺដើម្បីទប់ស្កាត់ការ ផ្តល់ហិរញ្ញប្បទានដោយលួចលាក់ និងការដាក់សម្ពាធដាយថាហេតុ ការត្រួតពិនិត្យទ្រព្យសម្បត្តិ របស់បេក្ខជនដែលជាប់ឆ្នោត កា រធានាឲ្យមានសមភាពរវាងបេក្ខជនទាំងអស់ដោយកំណត់ការ ចំណាយខ្ពស់បំផុត និងបង្កើត ឲ្យមានការដាក់ពិន័យផ្សេងៗ។ គណបក្សនិមួយៗត្រូវចាត់តាំងអ្នក

ទទួលខុសត្រូវខាងហិរញ្ញវត្ថុម្នាក់ ក្នុងការបង្កើតគណនីយុទ្ធនាការឃោសនារបស់គណបក្ស ហើយគណនីនេះនឹងត្រូវត្រួតពិនិត្យដោយគណៈកម្មការជាតិ គណនីយុទ្ធនាការឃោសនាបោះឆ្នោត និងហិរញ្ញប្បទាននយោបាយ។

លោក Robert A. Patterson ជាតំណាងមកពីអង្គការមូលនិធិអន្តរជាតិសម្រាប់ ប្រព័ន្ធបោះឆ្នោត (IFES) បានធ្វើបទបង្ហាញអំពីបទពិសោធន៍នៃការអនុវត្តន៍នៃហិរញ្ញវត្ថុនយោបាយ ដោយបានលើកយកប្រទេសចំនួន២មកធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា គឺប្រទេសអាហ្គានីស្ថាន និងប្រទេសកាណាដា។ លោកបានបង្ហាញថានៅប្រទេសអាហ្គានីស្ថានការគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ គឺស្ថិតនៅក្រោមបទបញ្ញារបស់គណៈកម្មាធិការបោះឆ្នោតឯករាជ្យមួយដែលនៅក្នុងបទបញ្ញានោះ បានកំណត់ពីការប្រើប្រាស់ធនធានរបស់រដ្ឋ របាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយពេលបោះឆ្នោតអំពីចំណូល និងចំណាយ និងការចេញផ្សាយនូវរបាយការណ៍ទាំងនោះជូនទៅសាធារណជន និងការទ ទួលទណ្ឌកម្មដោយមិនគោរពតាមបទបញ្ញាដែលមានចែង។ បន្តមកទៀត លោកបានបង្ហាញពីច្បាប់ហិរញ្ញវត្ថុពេលឃោសនាសហព័ន្ធនៅក្នុងប្រទេសកាណាដាដែលនៅក្នុងច្បាប់នោះ បានដាក់កំណត់ចំពោះការបរិច្ចាគទៅកាន់គណបក្សនយោបាយពីសាជីវកម្ម និងសហជីពការងារ និងដែនកំណត់ចំពោះប្រជាពលរដ្ឋកាណាដា ការជួយឧបត្ថម្ភពីរដ្ឋទៅឲ្យគណបក្សនិមួយៗដោយមានលក្ខ័ណ្ឌ ការដាក់កា រចំណាយខ្ពស់បំផុតពេលឃោសនាបោះឆ្នោតចំបោះគណបក្សនយោបាយ បេក្ខជន និងអ្នកដែលត្រូវបានតែងតាំង។ ចំណែកឯរបាយការណ៍ហិរញ្ញវត្ថុទាក់ទងទៅនឹងការចំណាយ និងចំណូលរបស់គណបក្សវិញត្រូវផ្ញើមកជូនមកស្ថាប័នឯករាជ្យមួយដែលមានតួនាទីតាមដាន និងពិនិត្យមើលការអនុវត្តន៍ច្បាប់របស់គណបក្សនយោបាយ និងបេក្ខជនដើម្បីយកមកចេញផ្សាយជូនសាធារណជន ហើយស្ថាប័ននេះនឹងរាយការណ៍ដោយផ្ទាល់ទៅរដ្ឋសភាទាក់ទងនិងប្រតិបត្តិការបោះឆ្នោត។ ចំណែកការល្មើសទៅនឹងច្បាប់នេះ និងការដាក់ទោសពិន័យជាប្រាក់ និងដាក់គុក និងការដាក់ទណ្ឌកម្មបន្ថែមទៀតដែលមាននៅក្នុងច្បាប់បោះឆ្នោតនៃប្រទេសកាណាដា។

លោក **សុកលៈ ទីប៉ោ** ជាអគ្គលេខាធិការរងតំណាងឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានមានបានលើកឡើងថាៈ

- មានភាពមិនសមធម៌មក្នុងការយកថវិកាជាតិ
- គណបក្សនយោបាយទាំងអស់ ត្រូវមានសីលធ៌មជៀសវាងបក្សពួកនិយម
- លោកមិនទាន់មានឃើញគណបក្សណា បង្ហាញការចំណាយច្បាស់លាស់ក្នុងពេលឃោសនា

បោះឆ្នោតម្តងៗ

– គ.ជ.ប មិនដែលពិភាក្សាជាមួយគណបក្ស ក្នុងការធ្វើហិរញ្ញវត្ថុនយោបាយពេលឃោសនាបោះឆ្នោត

– ការយករថយន្តរបស់រដ្ឋមកប្រើប្រាស់ជាមធ្យោបាយសម្រាប់ធ្វើការឃោសនាបោះឆ្នោត

– លោកសង្កេតឃើញថា សកម្មភាពរបស់បក្សមួយចំនួនសព្វថ្ងៃជាសកម្មភាពសមធម៌ ឬសកម្មភាពជាការឃោសនារកសន្លឹកឆ្នោត។

លោកក៏បានលើកឡើងផងដែរថា គោលជំហរនៃការធ្វើច្បាប់មិនមែនជាតួនាទីរបស់គ.ជ.បទេ ប៉ុន្តែក្នុងនាមរូបលោកផ្ទាល់ លោកសូមគាំទ្រក្នុងការធ្វើឲ្យមានច្បាប់ត្រួតពិនិត្យហិរញ្ញវត្ថុគណបក្សនេះពីព្រោះថា ប្រទេសយើងត្រូវការច្បាប់នេះបន្ទាប់ពីច្បាប់ប្រឆាំងអំពើពុករលួយដែលទើបត្រូវបានអនុម័តកាលពីពេលថ្មីៗនេះ លោកបន្ថែមទៀតថា បើយើងមានឆន្ទៈយើងត្រូវតែធ្វើឲ្យបាន។

លោក **គល់ បញ្ញា** ជានាយកប្រត្តិបត្តិនៃអង្គការខុមហ្វ្រែលបានធ្វើការសរុប និងថ្លែងសុន្ទរកថាបិទនៅក្នុងសិក្ខាសាលាថា ការធ្វើច្បាប់នេះឡើង គឺគ្មានគោលបំណងត្រួតត្រា ឬបន្ថយលុយ (ចំណូល និងចំណាយ)ការចាយលុយរបស់គណបក្សណាមួយទេ ប៉ុន្តែគោលការណ៍ និងការអនុវត្តន៍ដំបូងនេះ គឺគ្រាន់ចង់ឲ្យគណៈបក្សមានតម្លាភាពក្នុងការប្រើប្រាស់លុយឲ្យបានត្រឹមត្រូវ ក្នុងការដែលធានាឲ្យការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ យើងអាចរៀនសូត្រពីបណ្តាប្រទេសផ្សេងៗទៀតក្នុងការអនុវត្តន៍ច្បាប់ ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ ឬច្បា ប់ស្តីពីហិរញ្ញវត្ថុក្នុងពេលឃោសនាបោះឆ្នោត ពីព្រោះមានប្រទេសប្រហែលជា៧០%នៃប្រទេស ដែលមានការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យដែលកំពុងអនុវត្តច្បាប់នេះ។ លោកក៏បានមានប្រសាសន៍ទៀតថា លោកចង់ឲ្យមានការពិភាក្សានៅពេលក្រោយៗទៀត ពីព្រោះរឿងនេះមានសារៈសំខាន់ណាស់។

## ករណីសិក្សា ៖ ហិរញ្ញវត្ថុគណបក្សនយោបាយ នៅប្រទេសអាហ្វានីស្ថាន

កិច្ចព្រមព្រៀងទីក្រុងប៊ន (The Bonn Agreement) បានបង្កើតកម្មវិធីការងារឈ្លានពានមួយ (ពីខែធ្នូ ឆ្នាំ២០០១ ដល់ខែមិថុនា ឆ្នាំ២០០៤) ដើម្បីដឹកនាំព្រឹត្តិការណ៍ប្រជាធិបតេយ្យធំបី ដែលត្រូវបានរចនាឡើង ដើម្បីកសាងប្រទេសពីអ្នកកាន់អំណាចអន្តរកាល ទៅជារដ្ឋាភិបាលដែលត្រូវបានគេបោះឆ្នោតដោយត្រឹមត្រូវមួយ។ ព្រឹត្តិការណ៍ទីមួយ បានប្រារព្ធឡើងនៅក្នុងខែមិថុនា ឆ្នាំ ២០០២ ពេល Emergency Loya Jirga ជាក្រុមប្រឹក្សាជាន់ខ្ពស់មួយ (សមាជិករដ្ឋសភា ប្រធានក្រុមប្រឹក្សាខេត្ត និងស្រុក) ពិនិត្យមើលការផ្ដល់សច្ចាប័ននៃការគ្រប់គ្រងអន្តរកាល។ ព្រឹត្តិការណ៍ទីពីរ បានកើតមានឡើងនៃការព្រាងរដ្ឋធម្មនុញ្ញ និងដំណើរការប្រឹក្សា យោបល់ដែលបានសម្រេចជាមួយនឹងរដ្ឋធម្មនុញ្ញ Loya Jirga ដែលរដ្ឋធម្មនុញ្ញថ្មីបានអនុម័ត ជាផ្លូវការ។ រដ្ឋធម្មនុញ្ញ Loya Jirga ជាការកំណត់ពេលវេលាដើមដើម្បីឲ្យកើតឡើងនូវការដួលរលំក្នុងឆ្នាំ ២០០៣ ដែលត្រូវបានពន្យារពេលរហូតដល់ខែធ្នូ ឆ្នាំ២០០៣។

ព្រឹត្តិការណ៍ទីបី និងចុងក្រោយ ត្រូវបានប្រារព្ធឡើងនៃការបោះឆ្នោតជាតិ ដែលជាការកំណត់ពេលវេលាដើមសម្រាប់ខែមិថុនា ឆ្នាំ ២០០៤។ ទោះបីជាយ៉ាងណា ដោយសារតែកត្តាជាច្រើន ការបោះឆ្នោត ត្រូវបានពន្យារពេលនៅលើកដំបូង ហើយក្រោយមកទៀត បែងចែកទៅជាការបោះឆ្នោតប្រធានាធិបតី និងការបោះឆ្នោតសភា។

ច្បាប់បោះឆ្នោត បានផ្ដល់អំណាចផ្លូវការសម្រាប់ត្រួតពិនិត្យបញ្ហាហិរញ្ញវត្ថុនយោបាយទៅដល់ស្ថាប័នពីរៈ ការិយាល័យចុះឈ្មោះគណបក្សនយោបាយនៃក្រសួងយុត្តិធម៌ និងស្ថាប័នគ្រប់គ្រង ការបោះឆ្នោត ក្រោយ មកបង្កើតជាគណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ និងគណៈកម្មាធិការដោះស្រាយបណ្ដឹងបោះឆ្នោត។ គណៈកម្មាធិការរៀបចំការបោះឆ្នោត ឯករាជ្យ ទទួលខុស ត្រូវសម្រាប់ដំណើរការចុះឈ្មោះគណបក្សនយោបាយ ដូចដែលបានចែងកំណត់នៅក្នុងច្បាប់បោះឆ្នោត ដែលបានរាប់បញ្ចូលតម្រូវការប្រកាសព័ត៌មានពីហិរញ្ញវត្ថុ។ ដោយផ្អែកតាមច្បាប់ គណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ មានអំណាចត្រឹមតែត្រួត ពិនិត្យមើលទៅលើហិរញ្ញវត្ថុ គណបក្សនៅពេលចុះឈ្មោះ ដោយមិនមានអំណាច ដើម្បីដឹកនាំបទបញ្ជាជម្រះបញ្ជីស្ថានភាពហិរញ្ញវត្ថុទេ។

ស្ថាប័នគ្រប់គ្រងការបោះឆ្នោត មានអំណាច សម្រាប់គ្រប់បញ្ហាហិរញ្ញវត្ថុទាំងអស់ដែលទាក់ទងនឹងការបោះឆ្នោត ដូចមានចែងនៅក្នុងច្បាប់បោះឆ្នោត។ ស្ថាប័នគ្រប់គ្រងការបោះឆ្នោតមានការទទួលខុសត្រូវសម្រាប់ការប្រព្រឹត្តិទៅតាមច្បាប់ និងបង្ខំឲ្យអនុវត្ត ប៉ុន្តែបានប្រឈមទៅនឹងដែនកំណត់នៅក្នុងការបំពេញមុខងារទាំងនេះ ដោយសារតែការបន្ទឹងពេលវេលា ការដាក់កំហិតធនធាន និងប្រតិបត្តិការអាជ្ញាបញ្ជាពាក់ពន្ធ័នឹងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី។ ជា ឧទាហរណ៍ បេក្ខជនដែលបានតែងតាំង១៨រូប សម្រាប់ ឃោសនាបោះឆ្នោតជ្រើសរើសប្រធានាធិបតីបញ្ជូនរបាយការណ៍ត្រឹមតែពីរប៉ុណ្ណោះ ដែលបានតម្រូវនៅក្នុងបទបញ្ជា គឺ របាយការណ៍ចំណូល និង

ចំណាយ ហើយមិនមានការចង្អុលបង្ហាញពី អង្គការគ្រប់គ្រងការបោះឆ្នោតនៃការពិនិត្យមើលនីតិវិធីជាមួយនឹងបេក្ខជនទេ។

ការរាយការណ៍ពីហិរញ្ញវត្ថុពេលយុទ្ធនាការបោះឆ្នោត ដោយអ្នកចូលរួមឈរឈ្មោះបោះឆ្នោត (ដូចដែលបានប្រៀបធៀបទៅដល់ការរាយការណ៍ហិរញ្ញវត្ថុ ដែលកំពុងតែកើតមានឡើងដោយគណបក្សដែលបានចុះឈ្មោះ) គឺតែងតែងាយនឹងទទួលអារម្មណ៍ចំពោះកម្សោយនៃការអនុវត្តន៍នៅក្នុងការអភិវឌ្ឍន៍ប្រជាធិបតេយ្យ៖ អ្នកចូលរួមឈរឈ្មោះបោះឆ្នោតរឹងទទឹង និងការលាតត្រដាងដូចជា ព័ត៌មាន និងកង្វះខាតលទ្ធផលសម្រាប់ការរក្សារបាយការណ៍ និងការរាយការណ៍៖ គណបក្សដែលចាញ់ឆ្នោត ឬបេក្ខជនមានអារម្មណ៍ដឹង ទោះបីជាឥតមានកាតព្វកិច្ចដើម្បីអនុវត្តតាមកាតព្វកិច្ចរាយការណ៍ក្រោយការបោះឆ្នោត និងអាជ្ញាធរបោះឆ្នោតខ្វះខាត ធនធាន ឬអំណាចដើម្បី ស៊ើបអង្កេតឲ្យមានប្រសិទ្ធិភាព និ ងកាត់ទោសការបំពាន។ ឧបសគ្គទាំងនេះ កាន់តែបំភ័យឡើងនៅក្នុងសង្គមក្រោយជម្លោះ។

កត្តាដទៃទៀត ដែលប៉ះពាល់ដល់ការបង្ខំឲ្យអនុវត្ត និងការប្រតិបត្តិតាមច្បាប់ដែលមានតិចតួចកិច្ចខិតខំប្រឹងប្រែងដែលត្រូវបានធ្វើឡើងដោយអាជ្ញាធរដែលទទួលខុសត្រូវ ដើម្បីភ្ជាប់ជាមួយនឹងគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះលើបញ្ហាហិរញ្ញវត្ថុនយោបាយ។ ជាលទ្ធផលហិរញ្ញវត្ថុនយោបាយលេចឡើងនូវអវត្តមានបទប្បញ្ញត្តិ ដែលរួមចំណែកចំពោះមុខមាត់អវិជ្ជមាននៃអាជ្ញាធរទាំងនោះ ដោយគណបក្ស និង បេក្ខជន ដែលបានបង្ហាញក្នុងដំណើរការទាំងស្រុងជាមួយនឹងការសម្គាល់មជ្ឈធាតុនិយម (ភាពគ្មានជំនឿ)។

**មូលនិធិពីប្រភពដែលសង្គមពុំស្វាគមន៍ និងអ្នកទទួលដែលអាចបង្កបញ្ហា**

ទាំងច្បាប់ ស្តីពីគណបក្សនយោបាយ និងច្បាប់បោះឆ្នោត បានបង្កើតមូលនិធិដែលមានដែនកំណត់។ មាត្រា ១៥នៃច្បាប់គណបក្សនយោបាយ បាន កំណត់ធនធានដែលអាចអនុញ្ញាតចំនួន៥នៃមូលនិធិសម្រាប់គណបក្សនយោបាយ៖

១«វិភាគទានពីសមាជិកភាព

២«ការបរិច្ចាកដោយនីតិបុគ្គលចំពោះទឹកប្រាក់ចាប់ពី ២ លានអាហ្វានី ក្នុងមួយឆ្នាំ

៣«ចំណូលពីអចលនទ្រព្យ និងចលនទ្រព្យរបស់គណបក្ស

៤«ការឧបត្ថម្ភធនដោយរដ្ឋាភិបាលដែលទាក់ទងគ្នានៅក្នុងការបោះឆ្នោត

៥«វិភាគទានដទៃទៀតដោយសមាជិក

ច្បាប់បោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ថា បេក្ខជន និងគណបក្សមិនអនុញ្ញាតឲ្យទទួលមូលនិធិពីប្រភពបរទេស ឬប្រភពខុសច្បាប់នៅក្នុងប្រទេសឡើយ។

ប៉ុន្តែខណៈដែលច្បាប់ទាំងនេះផ្តល់សញ្ញាណចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីទទួលយកការប្រតិបត្តិបោះឆ្នោតដែលអាចទទួលយកបានជាអន្តរជាតិ ភាពពិតប្រាកដគឺថា អាជ្ញាធរបោះឆ្នោតបច្ចុប្បន្នខ្វះសមត្ថភាព ដើម្បីតាមដានឲ្យមានប្រសិទ្ធិភាព និងបង្ខំឲ្យអនុវត្តទិដ្ឋភាពនៃច្បាប់

នេះ។ ហេតុដូច្នេះ ប្រពន្ធ័ បច្ចុប្បន្នពឹងពាក់ទៅលើការប្រតិបត្តិតាមច្បាប់ដោយស្មគ្រចិត្តដែល គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបានយល់ដឹងតិចតួចពីនយោបាយ និងតម្រូវការ ឬ ដំណើរការហិរញ្ញវត្ថុបោះឆ្នោត។ នៅក្នុងការបោះ ឆ្នោតជ្រើសរើសប្រធានាធិបតី បញ្ហានេះបានធ្វើឲ្យ ខ្លាំងឡើងៗ ដោយការណែនាំនៃបទប្បញ្ញត្តិហិរញ្ញវត្ថុឃោស-នាបោះឆ្នោតត្រឹមតែ៤៨ម៉ោង មុន ពេលចាប់ផ្តើមនៃអំឡុងពេលឃោសនា ដោយមិនមានការប្រឹក្សាយោបល់ ឬហ្វឹកហាត់ជាមុន។ បេក្ខជន និងក្រុមរបស់ពួកគេ មិនមានពេលដើម្បីសិក្សាបទប្បញ្ញត្តិ និងទម្លាក់លើនីតិវិធី ដ៏សំខាន់នេះ ដើម្បីជួបរបាយការណ៍របស់ពួកគេដែលបានតម្រូវ។ ជាលទ្ធ ផល ភាពសំខាន់របស់ពួកគេ បានបាត់ បង់នៅក្នុងសម្លេងទូទៅ បង្កើតដោយការឃោសនាបោះឆ្នោតទាំងមូល។

គណបក្សនយោបាយ និងបេក្ខជនដែលបានឈរឈ្មោះ ត្រូវបានកំណត់បន្តិចបន្តួចនៅក្នុង លទ្ធភាពរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងបញ្ហាហិរញ្ញវត្ថុដោយកង្វះខាតនៃរចនាសម្ពន្ធ័ហិរញ្ញវត្ថុ ទំនើបក្នុងប្រទេស។ ជាឧទា ហរណ៍ នៅពេលដែលច្បាប់គណបក្សនយោ បាយបានប្បញ្ញត្តិ នៅក្នុង ខែកញ្ញា ឆ្នាំ ២០០៣ មិនមានធនាគារឯកជនប្រតិបត្តិការនៅក្នុងប្រទេសអាហ្វានីស្ថាន ដែលអាច ឲ្យ គណបក្សតម្កល់មូលនិធិរបស់ពួកគេទេ។ ពាណិជ្ជកម្មនៅក្នុងប្រទេសនេះ ទោះបីជាធ្វើឡើងដោយ ស្ថាប័នអន្តរជាតិ ឬអ្នកជំ នួញអាហ្វានីស្ថាន មាន ជាអាទិ៍ដឹកនាំលើមូលដ្ឋាននៃថវិកាមួយ។ មានតិច តួចណាស់ជាក្រុមហ៊ុនគណនេយ្យសាធារណៈ ដែលណែ នាំវិជ្ជាជីវៈ ឬសវនកម្មឯករាជ្យ ដែលគួរតែ អាចត្រូវបានប្រតិបត្តិនៅពេលនោះ។ ការផ្តល់នូវបរិយាកាស នេះ វា មិនមានអ្វីភ្ញាក់ផ្អើលទេដែល គណបក្សនយោបាយខ្លួនគេផ្ទាល់ មានដែនកំ ណត់នៅក្នុងការប្រើប្រាស់ ឬលទ្ធភាពដើម្បីអភិវឌ្ឍន៍ ការគ្រប់គ្រងហិរញ្ញវត្ថុ និងជំនាញរាយការណ៍ដែលត្រូវការដើម្បីអនុវត្ត តាមឲ្យបានត្រឹមត្រូវជាមួយ និងហិរញ្ញវត្ថុពេលឃោសនាដែលតម្រូវ។

រដ្ឋាភិបាលគួរតែទៅឲ្យបានឆ្ងាយ ដើម្បីសម្រាលក្តីកង្វល់ទាំងឡាយមកលើប្រាក់ទុនពីប្រភព ខុសច្បាប់ក្នុងប្រទេស ឬអន្តរជាតិណាមួយ ដោយទទួលយករបបនៃការឧបត្ថម្ភធនបោះឆ្នោតពេញ លេញ សម្រាប់ ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី។ រដ្ឋាភិបាលផ្តល់ប្រាក់ឃោសនាបោះឆ្នោត ទៅបេក្ខជនគណបក្សនយោបាយឈរឈ្មោះ បានបន្ថយឥទ្ធិពលដែលមានសក្តានុពលនៃថវិកាពី ប្រភពខុសច្បាប់ និងលើកទឹកចិត្តកា ន់តែច្រើនឡើងចំពោះ «ការកម្រិតទីលានប្រណាំងប្រជែង៖ Level playing field»។

## ហិរញ្ញវត្ថុនយោបាយពេលឃោសនាបោះឆ្នោតនៅអាហ្វានីស្ថាន

ក្នុងឆ្នាំ ២០០៩ គណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យបានអនុម័តបទបញ្ញាស្តីពី ការ ប្រកាសព័ត៌មានហិរញ្ញវត្ថុនយោបាយពេលឃោសនាបោះឆ្នោត ដែល បានប្បញ្ញត្តិដើម្បីត្រួតពិនិត្យ លើហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោតរបស់បេក្ខជននាយករដ្ឋមន្ត្រី។ បទបញ្ញានេះ តម្រូវឲ្យបេក្ខជន ប្រកាសពីចំណូល និង ចំណាយ ដែលរាប់បញ្ចូលទាំង ការហាមប្រាមវិភាគទាននយោបាយពីក្រុម ហ៊ុន សាជីវកម្ម និងអង្គការ។ វិភាគទានទាំងនោះ ត្រូវកម្រិតចំពោះបេក្ខជ នដែលបានចុះ ឈ្មោះបោះ

ឆ្នោត។ ចំណូលក៏រាប់បញ្ចូល ការផ្តល់នូវទំនិញ និងសេវាដោយមិនគិតថ្លៃ ឬបញ្ចុះតម្លៃ និងប្រាក់ កម្ចីផងដែរ។ គ្រប់បេក្ខជនទាំងអស់ ត្រូវតម្រូវឲ្យចេញវិក័យបត្រទៅគ្រប់វិភាគទានច្រើនជាង៥.០០០ អាហ្វានី (ប្រហែល១០០ដុល្លារសហរដ្ឋអាមេរិក) ហើយត្រូវកត់ត្រានូវរាល់ វិភាគទានតូចតាចនៅក្នុងសៀវភៅបញ្ជីវិភាគទានរបស់បេក្ខជន។ ចាត់ទុកថា ជាវិភាគទានដែន កំណត់មួយសម្រាប់បុគ្គលតែបេក្ខជននៅតែអនុញ្ញាតឲ្យទទួលថវិកាពីគណបក្សនយោបាយរបស់ពួកគេ។ ការ បើកចំហនេះ ជាចន្លោះទំនេរមួយដែលអាចឲ្យអ្នកធ្វើគុណប្រយោជន៍ បញ្ជូនវិភាគទាន របស់ពួកគេ តាមរយៈគណបក្សនយោបាយ និងចៀសវាងការប្រកាសព័ត៌ មាន។ ការចំណាយ គឺត្រូវបានកំណត់ថា ជាការចំណាយផ្សេងៗដែលធ្វើឡើងសម្រាប់រាល់ទំនិញ អចលទ្រព្យ ទ្រព្យ សម្បត្តិ សេវា ឬការសម្របសម្រួលដើម្បីប្រើប្រាស់នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។ មិនមានការ ហាមប្រាម ឬកំណត់ការចំណាយទេ ប៉ុ ន្តែបេក្ខជន ត្រូវបានតម្រូវឲ្យរក្សាទុកវិក័យបត្រសម្រាប់ការចំណាយលើសពី ៥.០០០ អាហ្វានី (ប្រហែល១០០ដុល្លារសហរដ្ឋអាមេរិក) និងកត់ត្រាទុករាល់ការចំណាយតូចតាចនៅក្នុងសៀវភៅចំណាយ។

ការប្រកាសព័ត៌មាន គឺតម្រូវឲ្យប្រកាស ទ្រព្យសម្បត្តិ ដែលមានតម្លៃលើសពី ២.០០០ដុល្លារសហរដ្ឋអាមេរិក មុនពេលបោះឆ្នោត វិភាគទានពេលយុទ្ធនាការរបស់ពួកគេ និងការចំណាយទៅកាន់គណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ។ របាយការណ៍ទ្រព្យសម្បត្តិ នឹងត្រូវរក្សាទុកដោយសម្ងាត់ដោយគណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ។ អំឡុងពេលឃោសនាបោះឆ្នោតបេក្ខជន គឺតម្រូវឲ្យរាយការណ៍ចំណូល និងចំណាយរៀងរាល់ពីរសប្តាហ៍ម្តង។ ក្រោយការបោះឆ្នោតគ្រប់ចំណូល និងចំណាយទាំងអស់ គឺតម្រូវឲ្យរាយ ការណ៍ ដោយភ្ជាប់ជាមួយនឹងវិក័យបត្រ សម្រាប់វិភាគទាន/ការចំណាយធំដុំ (លើសពី១០០ដុល្លារសហរដ្ឋអាមេរិក) និងសៀវភៅកត់ត្រាសម្រាប់វិភាគទាន/ការចំណាយ (១០០ដុល្លារសហរដ្ឋអាមេរិក និងក្រោម )។ គ្រប់ ព័ត៌មានដែលបានបញ្ជូនដោយបេក្ខជននឹងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ក្រោយពេលបោះឆ្នោត លើកលែងតែបុគ្គលដែលបានចូលរួមវិភាគទាន សរុបតិចជាង ១០០០ដុល្លារសហរដ្ឋអាមេរិក ទៅឲ្យយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីចៀសវាងការយាយី ឬកម្មពៀរដែលអាចកើតមានឡើង។

សម្រាប់ការត្រៀមត្រួតពិនិត្យហិរញ្ញវត្ថុពេលឃោសនា នៅក្នុងពេលបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ២០០៩ ប្រទេសអាហ្វានីស្ថានបានរៀបចំបង្កើត៖ ស្ថាប័នហិរញ្ញវត្ថុនយោបាយមួយសៀវភៅណែនាំបេក្ខជន និងទម្រង់របាយការណ៍ តម្រូវការរបាយការណ៍បន្ថែមដែលសម្រេចចិត្តដោយគណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ អន្តរកម្មរវាងគណៈកម្មាធិការបោះឆ្នោតឯករាជ្យ និងបេក្ខជន ហើយនិងហិ រញ្ញវត្ថុខាងជំនួញ និងឈានទៅដល់ ការត្រួតពិនិត្យតួនាទីនៃប្រពន្ធ័ផ្សព្វផ្សាយចំពោះហិរញ្ញវត្ថុនយោបាយពេលឃោសនាបោះឆ្នោត។

នៅពេលបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ២០០៩ បេក្ខជនជាច្រើនបានបញ្ជូនរបាយការណ៍ នៅ ក្នុងឱកាសផ្សេងៗគ្នាដោយផ្អែកតាមប្រភេទដែលត្រូវរាយការណ៍។ ប្រភេទដែលត្រូវ

របាយការណ៍រាប់បញ្ចូល៖
»ហិរញ្ញវត្ថុផ្នែកជំនួញរបស់បេក្ខជន
»គណនីធនាគារពេលឃោសនាបោះឆ្នោត
»ទ្រព្យសម្បត្តិ និងបំណុលរបស់បេក្ខជន
»របាយការណ៍ចំណូល និងចំណាយប្រចាំពីរសប្តាហ៍ម្តង អំឡុងពេលឃោសនា និង
»របាយការណ៍ក្រោយបោះឆ្នោត (ចំណូល ចំណាយ និងអតិរេក /ឳនភាពនៃគណនី ពេលឃោសនា)

**តារាង ៖ កម្រិតនៃការអនុវត្តតាមដោយបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ២០០៩ ៖**

| របាយការណ៍ | បានបញ្ជូនទាន់ពេល | បានបញ្ជូន |
|---|---|---|
| ជំនួញហិរញ្ញវត្ថុ | ៩០ % | ១០០ % |
| គណនីធនាគារសម្រាប់ការឃោសនា | ៩០ % | ១០០ % |
| ទ្រព្យសម្បត្តិ និងបំណុល | ៩០ % | ១០០ % |
| របាយការណ៍ទី មួយ (ពី ថ្ងៃទី ១៦»២៨ ខែមិថុនា) | ៣៤ % | ៨៥ % |
| របាយការណ៍ទី ពីរ (ពីថ្ងៃទី ២៩ ខែមិថុនា ដល់ ថ្ងៃទី ២៧ ខែកក្កដា) | ៨០ % | ៩៣ % |
| របាយការណ៍ទី បី (ពីថ្ងៃទី ១៨ ខែកក្កដា ដល់ថ្ងៃទី ០១ ខែសីហា) | ៧៣ % | ៨០ % |
| របាយការណ៍ទី បួន (ពីថ្ងៃទី ០២ ដល់ថ្ងៃទី ១៧ ខែសីហា) | ៨៣ % | ៨៣ % |
| របាយការណ៍ចុងក្រោយ | ៥៦ % | ៥៦% |
| ការអនុវត្តតាមជាមធ្យម | ៧៥ % | ៨៨% |

## ការដាក់ទណ្ឌកម្មប្រឆាំងនឹងការមិនអនុវត្តតាម

ទណ្ឌកម្មប្រឆាំងនឹងបេក្ខជនដែលមិនអនុវត្តតាម អាចនឹងអនុវត្តតាមបទបញ្ជារបស់គណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ ស្តីពី ការប្រកាសព័ត៌មានហិរញ្ញវត្ថុនយោបាយពេលឃោសនា ឬតាមរយៈច្បាប់ បោះឆ្នោត។ ទណ្ឌកម្មអាចមានលំដាប់ចាប់ពីការព្រមាន ដល់ការពិន័យដែលមិនលើសពី២០០០ដុល្លារសហរដ្ឋអាមេរិក រហូតដល់ដកបេក្ខជនចេញពីបញ្ជីបេ ក្ខជន ឬហាម

ប្រាមបេក្ខភាពរបស់ពួកគេនៅពេលបោះឆ្នោតក្រោយៗទៀត។ ស្ថាប័នដែលទទួលខុសត្រូវដាក់ទណ្ឌកម្មអ្នកដែលមិនអនុវត្តតាម គឺគណៈកម្មាធិការដោះស្រាយបណ្តឹងបោះឆ្នោត។

**តារាង៖ ការដាក់ទណ្ឌកម្មខ្លះៗរបស់ គណៈកម្មាធិការដោះស្រាយបណ្តឹងបោះឆ្នោត ប្រឆាំងនឹងអ្នកមិនបញ្ជូនរបាយការណ៍សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ឆ្នាំ ២០០៩**

| បេក្ខជន | របាយការណ៍ខកខាន | មូលហេតុ | ពិន័យ (អាហ្វានី) | ការធ្វើតាមពេលក្រោយ |
|---|---|---|---|---|
| Abdul Gafur Zuri | 2nd | ជាប់រវល់បើកយុទ្ធនាការឃោសនា | 5 000 ($100) | បានធ្វើតាម |
| Abdul Majid Samin | 2nd | អ្នកប្រឹក្សាហិរញ្ញវត្ថុ ឈឺ | 5 000 ($100) | បានធ្វើតាម |
| Gul Ahmad Yama | 2nd | ញាតិជិតស្និទត្រូវបានវាយប្រហារ ដោយគ្រាប់បែកអត្តឃាដ | 20 000 ($400) | ដកចេញ |
| Ghulam Mohammed Regei | 2nd | គ្មានមូលហេតុ | 5 000 ($100) | បានធ្វើតាម (ក្រោយមកដកចេញ) |
| Nasrullah Baryalay Arsalai | 2nd | មិនមានពេលដើម្បីរាយការណ៍ | 20 000 ($400) | ដកចេញ |

ទោះបីជាយ៉ាងណា ការដាក់ទណ្ឌកម្មជាច្រើនត្រូវបានចេញដោយគណៈកម្មាធិការដោះស្រាយបណ្តឹង បោះឆ្នោតសម្រាប់ករណីជាច្រើន ពិសេសទាក់ទងនឹងការបំពាននៃធនធានរដ្ឋ។ ទស្សនីយភាពដ៏ធំបំផុត គឺ គណៈកម្មាធិការដោះស្រាយបណ្តឹងបោះឆ្នោត បានពិន័យ Mohammed Kariri បេក្ខជនអនុប្រធានាធិបតី ករណី លិខិតឃោសនាគាំទ្រប្រធានាធិបតី Hamid Karzai ដែលកំពុងកាន់ដំណែង សម្រាប់ការប្រើប្រាស់ ឧទ្ធម្ភាគចក្រក្រសួងការពារជាតិ៣គ្រឿង ក្នុង គោលបំណងឃោសនាបោះឆ្នោត។ យុទ្ធនាការ Karzai និងក្រសួងអប់រំនៅ Badakhshan ត្រូវបានព្រមាន ព្រមទាំងពិន័យ 30 000 **អាហ្វានី (ប្រហែល** $600) សម្រាប់ការប្រើប្រាស់តង់ដែលបានឧបត្ថម្ភដោយ UNICEF សម្រាប់គោលបំណងឃោសនាបោះឆ្នោត។ ប្រធាន ស្ថានីយវិទ្យុ និងទូរទស្សន៍នៅក្នុងប្រទេសអាហ្វានីស្ថាន (RTA) ដែលជាស្ថានីយទូរទស្សន៍ និងវិទ្យុរបស់ រដ្ឋាភិបាលនៅ Baghlan ត្រូវទទួលពិន័យសម្រាប់ការដាក់តាំងរូប ប្រធានាធិបតី Karzai នៅលើយានយន្តរបស់ RTA។

**គុណវិបត្តិ/ចំណុចខ្សោយ នៅក្នុងហិរញ្ញវត្ថុនយោបាយអាហ្វានីស្ថាន**

»ការប្រកាសព័ត៌មានហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោត បានបញ្ញត្តិត្រឹម ក្នុងបទបញ្ជារបស់គណៈកម្មាធិការបោះឆ្នោតឯករាជ្យ ដែលមិនមានចែងនៅក្នុងច្បាប់បោះឆ្នោត។

»មិនមានដែនកំណត់សម្រាប់ការចំណាយរបស់បេក្ខជនបោះឆ្នោត។

»មិនមានដែនកំណត់ ជាបទ បញ្ញត្តិ សម្រាប់វិភាគទានរបស់គណបក្សនយោបាយ ចំពោះបេក្ខជនរបស់ពួកគេ។

»ខ្វះថវិកាសាធារណៈសម្រាប់ឃោសនាបោះឆ្នោត ដែលបើកចំហរដល់ការបំពានធនធានរដ្ឋ និងវិភាគទានខុសច្បាប់។

## ករណីសិក្សា ៖ ហិរញ្ញវត្ថុគណបក្សនយោបាយ នៅប្រទេសប្រទេសឥណ្ឌូនេស៊ី

ចាប់តាំងពីឆ្នាំ១៩៩៩ ប្រទេសឥណ្ឌូនេស៊ីដែលធ្លាប់ជារដ្ឋដែលប្រកាន់យករបបគណបក្សដឹកនាំតែមួយនោះ បានប្រែក្លាយជាប្រទេសប្រជាធិបតេយ្យថ្មីមួយទៀតដែលមានការចូលរួមប្រកួតប្រជែងពីគណបក្សរហូតដល់៤៣គណបក្សនយោបាយ ហើយមាន៤១គណបក្សដែលមាន អាសនៈក្នុងសភា។

ដូច្នេះវាមិនមែនជាការភ្ញាក់ផ្អើលទេ ដែលប្រទេសទើបនឹងទទួលយករបបប្រជាធិបតេយ្យនេះប្រឈមនឹងបញ្ហាជាច្រើន ដែលក្នុងនោះហិរញ្ញវត្ថុគណបក្សនយោបាយក៏ជាបញ្ហាចោទមួយដែរ។ ប្រទេសឥណ្ឌូនេស៊ីបានបញ្ញត្តិនូវបទបញ្ញាទាក់ទងនឹងហិរញ្ញវត្ថុគណបក្សនយោបាយ ស្របពេលនឹងការបង្កើតច្បាប់គណបក្សនយោបាយ និងការកែប្រែការបោះឆ្នោតដើម្បីឆ្លើយតបនឹងភាពជាក់ស្តែងនៃនយោបាយ។ ទោះបីជាបទបញ្ញាថ្មីនេះ បានកំណត់ពីកំរិតនៃវិភាគទានទៅកាន់គណបក្សនយោបាយ និងតំរូវឲ្យគណបក្សនយោបាយធ្វើនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនក៏ដោយ ក៏មិនមានការបែងចែកច្បាស់អំពីហិរញ្ញវត្ថុគណបក្សនយោបាយ និងហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនោះទេ ហើយជាងនេះទៅទៀតក៏មិនមានការកំណត់ឲ្យបានច្បាស់លាស់ផងដែរនូវរយៈពេលនៃយុទ្ធនាការបោះឆ្នោត។ ដូច្នេះបេក្ខជនគណបក្សនយោបាយព្រមទាំងអ្នកអង្កេតការណ៍តែងតែមានការយល់ច្រឡំអំពីអ្វីដែលច្បាប់អនុញ្ញាតនិងអ្វីដែលច្បាប់ហាមឃាត់។

***ការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយនៅឥណ្ឌូនេស៊ី***ផ្តោតសំខាន់ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ សំរាប់ការបោះឆ្នោតនៅឥណ្ឌូនេស៊ីដោយអនុលោមតាមមាត្រាខ្លះនៃច្បាប់ ស្តីពីការបោះឆ្នោតទូទៅនៃគណបក្សនយោបាយ។

### បញ្ហាច្បាប់ និងយុត្តាធិការ

ការគ្រប់គ្រង និងធ្វើរបាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយនៅក្នុងប្រទេសឥណ្ឌូនេស៊ីជាបន្ទុករបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត(KPU) តែក្នុងអំឡុងពេលឃោសនាបោះឆ្នោតប៉ុណ្ណោះ។ ច្បាប់លេខ២ឆ្នាំ១៩៩៩ ស្តីពីគណបក្សនយោបាយ បានផ្តល់អំណាចទូទៅទៅឲ្យតុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីក្នុងការត្រួតពិនិត្យ និងពង្រឹងការអនុវត្តន៍បទបញ្ញានៃគណបក្សនយោបាយ។ ជំពូក៦នៃច្បាប់នេះដែរ ក៏បានបញ្ញត្តិមាត្រាមួយចំនួនស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយផងដែរ។ ច្បាប់នេះបានចែងក្នុងមាត្រានូវដែនកំណត់នៃប្រភព និងចំនួនទឹកប្រាក់ដែលអាចធ្វើជាអំណោចដល់គណបក្សនយោបាយ និងតំរូវឲ្យគណបក្សនយោបាយធ្វើនូវ

របាយការណ៍អំពីសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួនទៅកាន់តុលាការកំពូល។ របាយការណ៍របស់IFES ដែលនិយាយអំពីថវិកានយោបាយបានកត់សំគាល់នូវចំនុចរួម និងភាពមិនស្របគ្នានៃការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សកំណត់ដោយច្បាប់ ស្តីអំពីគណបក្សនយោបាយ និងច្បាប់ស្តីការបោះឆ្នោតទូទៅ (ច្បាប់លេខ២ និងច្បាប់លេខ៣) អញ្ញមញ្ញភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយសំរាប់ការឃោសនាបោះឆ្នោតដែលកំណត់ដោយច្បាប់បោះឆ្នោត និងការគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុនៃគណបក្សនយោបាយកំណត់ដោយច្បាប់ ស្តីគណបក្សនយោបាយនៅមានភាពមិនច្បាស់លាស់នៅឡើយ។ យ៉ាងណាមិញ មានការពន្យល់បន្ថែមនៅក្នុងច្បាប់បោះឆ្នោតដែលបែងចែកថវិការគណបក្សនយោបាយ ច្បាប់ទាំងពីរនេះសុទ្ធតែតំរូវឲ្យគណបក្សនយោបាយធ្វើនូវរបាយការណ៍ហិរញ្ញវត្ថុ មុនពេលបោះឆ្នោត១៥ថ្ងៃមុនពេលបោះឆ្នោត។ តែមាននូវភាពមិនស្របគ្នាមួយត្រូវបានកត់សំគាល់រវាងរបបក្នុងការធ្វើរបាយការណ៍កំណត់ដោយច្បាប់ ស្តីពីគណបក្សនយោបាយ និងរបាយការណ៍ក្រោយពេលបោះឆ្នោតតំរូវដោយច្បាប់បោះឆ្នោត។ ច្បាប់គណបក្សនយោបាយតំរូវឲ្យគណបក្សនយោបាយធ្វើរបាយការណ៍ហិរញ្ញវត្ថុ៣០ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ចំណែកឯច្បាប់បោះឆ្នោតវិញតំរូវឲ្យគណបក្សនយោបាយធ្វើរបាយការណ៍ហិរញ្ញវត្ថុ២៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។ មាត្រា១៥នៃច្បាប់ ស្តីពីគណបក្សនយោបាយក៏បានរាប់បញ្ចូលផងដែរនូវកតព្វកិច្ចរបស់គណបក្សនយោបាយក្នុងការធ្វើរបាយការណ៍ប្រចាំឆ្នាំ។

**អំណាចដាក់ទណ្ឌកម្មចំពោះគណបក្សនយោបាយ**

ច្បាប់ស្តីពីគណបក្សនយោបាយ បានផ្តល់អំណាចទៅឲ្យតុលាការក្នុងការដាក់ទណ្ឌកម្មដូចជាៈ

១. តុលាការកំពូលនៃសាធារណរដ្ឋតណ្ឌូនេស៊ី ដាក់ទណ្ឌកម្មរដ្ឋបាលក្រោមរូបភាពជាការផ្អាកវិភាគទានរបស់រដ្ឋទៅឲ្យគណបក្សនយោបាយ បើគណបក្សនយោបាយត្រូវបានរកឃើញថា បានបំពានទៅលើមាត្រា១៥ នៃច្បាប់នេះ។

២. តុលាការកំពូលនៃសាធារណរដ្ឋតណ្ឌូនេស៊ី ដកសិទ្ធិចូលរួមក្នុងការបោះឆ្នោតរបស់គណបក្សនយោបាយ បើគណបក្សនយោបាយមិនគោរពតាមមាត្រា១៣ និង១៤ដែលហាមឃាត់ការធ្វើពាណិជ្ជកិច្ចរបស់គណបក្សនយោបាយ កំណត់ពីកំរិតនៃវិភាគទានចូលគណបក្ស និងតំរូវឲ្យគណបក្សមានរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

៣. ការដកហូតសិទ្ធិដូចដែលបានចែងក្នុងចំណុចខាងលើ ធ្វើឡើងបន្ទាប់ពីស្តាប់ការពិចារណារបស់គណបក្សនយោបាយ និងតុលាការកំពូល។

## ប្រតិបត្តិការក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ១៩៩៩

បញ្ហាទាក់ទិននឹងការគ្រប់គ្រងនិងការផ្សព្វផ្សាយហិរញ្ញវត្ថុគណបក្សនយោបាយ នាសម័យបោះឆ្នោតឆ្នាំ១៩៩៩នៅឥណ្ឌូនេស៊ី បានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពមិនច្បាស់លាស់នៃទំនួលខុសត្រូវផ្នែកយុត្តាធិការកំណត់ដោយច្បាប់នយោបាយថ្មី ក៏ដូចជាផ្នែករដ្ឋបាលដែលខ្វះបទពិសោធន៍ក្នុងវិស័យនេះដែរ។ តុលាការកំពូលមើលទៅហាក់ដូចជា មានកតព្វកិច្ចកំណត់នូវគោលការណ៍រដ្ឋបាលនិងកាន់តួនាទីរបស់ខ្លួនតាមការកំណត់នៃច្បាប់គណបក្សនយោបាយ ដែលសមត្ថកិច្ចនេះមានផងដែរចំពោះយុទ្ធនាការឃោសនាបោះឆ្នោត។

នៅថ្ងៃទី២០ មីនា ឆ្នាំ១៩៩៩ តុលាការកំពូលចេញនូវសេចក្តីសំរេចមួយដែលកំណត់ពីបទបញ្ជាសំរាប់ត្រួតពិនិត្យគណបក្សនយោបាយ និងអំណាចរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្មទៅលើគណបក្សនយោបាយក្នុងករណីបំពានច្បាប់គណបក្សនយោបាយ។ បទបញ្ជានេះកំណត់ផងដែរនូវទំរង់របាយការណ៍សកម្មភាពហិរញ្ញវត្ថុគណបក្សនយោបាយ បង្កាន់ដៃអំណោយដែលបានទទួលនិងចំណាយ។ ផ្ទុយទៅវិញ បទបញ្ជាដែលចេញពីសេចក្តីសំរេចរបស់តុលាការកំពូលនេះមិនមាន កំលាំងគតិយុត្តចាប់បង្ខំដល់គណបក្សនយោបាយនោះទេ ចំណែកគណបក្សនយោបាយវិញ ក៏ហាក់ដូចជាមិនបានទទួលស្គាល់កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ សំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនេះទៅឲ្យតុលាការកំពូលដែរ។ តែចុងក្រោយ ដោយមិនចាំបាច់មានការកំណត់ដោយច្បាប់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឥណ្ឌូនេស៊ី(KPU) បានសម្រុះសម្រួលការធ្វើរបាយការណ៍ហិរញ្ញវត្ថុទាំងពីរដែលកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ស្តីពីគណបក្សនយោបាយដោយមិនខ្វល់ពីកាលកំណត់នៃរបាយការណ៍ដែលចែងដោយច្បាប់ទាំងពីរខាងលើ ហើយដោយចតចំលងរបាយការណ៍ហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលគណបក្សនយោបាយផ្ញើមកឲ្យរួចផ្ញើទៅតុលាការកំពូល។

ដូច្នេះក្នុងករណីនេះKPU រុញនូវបន្ទុកក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះការមិនគោរព ឬរំលោភបំពានទាក់ទិននឹងការធ្វើរបាយការណ៍ហិរញ្ញវត្ថុនេះទៅឲ្យតុលាការកំពូល។ ដើម្បីអនុវត្តតួនាទីដែលកំណត់ដោយច្បាប់គណបក្សនយោបាយនេះ តុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានបង្កើតនូវនាយកដ្ឋានមួយដែលទទួលបន្ទុកការងារនយោបាយ។ នាយកដ្ឋាននេះមានសមាជិក៦នាក់ រាប់បញ្ចូលទាំងនាយកផងដែរ។ នាយកត្រូវធ្វើរបាយការណ៍ទៅឲ្យបញ្ជិការ ដែលជាអគ្គលេខាធិកានៃតុលាការកំពូល។ ជាគោលការណ៍នាយកមានតួនាទីបញ្ជូននូវករណីដែលកើតឡើងពីការគ្រប់គ្រងគណបក្សនយោបាយទៅកាន់បញ្ជិការ។ នាយកមានតួនាទីសង្ខេបរបាយការណ៍

ហិរញ្ញវត្ថុដែលទទួលបានពីគណបក្សនយោបាយ ហើយផ្ញើបន្តនូវសេចក្ដីត្រួតពិនិត្យរបស់ខ្លួនទៅឲ្យបញ្ជិការនៃតុលាការ។

យោងតាមច្បាប់ ស្ដីពីគណបក្សនយោបាយ របាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ គួរតែត្រូវបានត្រួតពិនិត្យដោយហេរញ្ញិកសាធារណៈតែងតាំងដោយតុលាការកំពូល។ ជាអកុសល តុលាការកំពូលមិនមានថវិកាគ្រប់គ្រាន់ ដើម្បីជួលគណនេយ្យករនោះទេ។ យ៉ាងណាក៏ដោយ ទោះជាតុលាការជួលគណនេយ្យករ ក៏តួនាទីរបស់គណនេយ្យករនេះ មានកំរិតត្រឹមការត្រួតពិនិត្យថាតើថវិការដែលទទួល និងចំណាយដោយគណបក្សនយោបាយត្រឹមត្រូវតាមការកំណត់ដោយច្បាប់ដែរឬទេ ដោយយោងតាមពត៌មានដែលបានផ្ដល់ឲ្យតាមរបាយការណ៍។ ដោយសារការខ្វះនូវរូបមន្តគណនាច្បាស់លាស់ និងការទទួលស្គាល់នូវអំណោយមិនស្របច្បាប់ និងការចំណាយមិនត្រឹមត្រូវមួយចំនួន តុលាការកំពូលមិនទំនងជាអាចលាតត្រដាងពីការបំពានទៅលើបទបញ្ញត្តិដែលចែងពីហិរញ្ញវត្ថុគណបក្សនយោបាយនៃច្បាប់ ស្ដីពីគណបក្សនយោយបាយនោះទេ។ ដូច្នេះច្បាប់ស្ដីពីគណបក្សនយោបាយ បានផ្ដល់នូវសក្ដានុពលសំរាប់ការពិនិត្យពិច័យបញ្ជីហិរញ្ញវត្ថុគណបក្សនយោបាយតិចជាងបទបញ្ញត្តិ ស្ដីពីហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនៃច្បាប់បោះឆ្នោត។ ក្នុងឆ្នាំ១៩៩៩ សំរាប់របាយការណ៍មុននិងក្រោយការបោះឆ្នោត KPU បានតែងតាំងគណនេយ្យករសាធារណៈសំរាប់គណបក្សនយោបាយនីមួយៗ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ដើម្បីត្រួត ពិនិត្យរបាយការណ៍របស់ពួកគេ។ យ៉ាងណាមិញ ការងាររបស់គណនេយ្យករនេះមិនសូវជាមានប្រសិទ្ធិភាពនោះទេ ដោយរបាយការណ៍របស់គណបក្សនយោបាយតែងតែមិនមានលក្ខណៈល្អិតល្អន់ ហើយតែងតែមិនភ្ជាប់នូវឯកសារយោង។ ដូច្នេះវាគ្រាន់ជាការត្រួតពិនិត្យទៅលើភាពមិនសមស្រប ឬការបំពានច្បាប់ប៉ុណ្ណោះ តែគណនេយ្យករមិនមានអំណាចដើម្បីស៊ើបអង្កេតលើបញ្ហាទាំងនេះ និងទាមទារឯកសារបន្ថែមនោះទេ។ ចំណែកតុលាការកំពូលវិញ ទោះជាតុលាការជួលគណនេយ្យករសាធារណៈ ដើម្បីពិនិត្យបញ្ជីរបាយការណ៍គណបក្សនយោបាយក៏ដោយ នាយកដ្ឋានទទួលបន្ទុកកិច្ចការនយោបាយនៅក្នុងតុលាការ ហាក់ដូចជាគ្មានអំណាចឯករាជ្យដើម្បីប្ដឹងគណបក្សនយោបាយដែលបានរំលោភបំពានច្បាប់នោះទេ។ ករណីនេះតុលាការបែរជារង់ចាំបណ្ដឹងពីខាងក្រៅទៅវិញ។

តុលាការសំរួលដល់សាធារណជន ក្នុងការត្រួតពិនិត្យរបាយការណ៍គណបក្សនយោបាយតាមរយៈការសរសេរសំណើរទៅអគ្គលេខាធិការតុលាការ។ ក៏ប៉ុន្តែមិនមាននូវយន្តសាស្ត្រក្នុងការផ្សព្វផ្សាយជាសាធារណៈ និងការកាត់សេចក្ដីលើបណ្ដឹងណាមួយត្រូវបានធ្វើដោយតុលាការនៅឡើយទេ

ដោយសារមិនទាន់មានបុគ្គល គណបក្សនយោបាយ ឬអ្នកយកសារពត៌មានណាមួយបានស្នើសុំទៅតុលាការ  ដើម្បីត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយនៅឡើយ។ បច្ចុប្បន្នតួនាទីរដ្ឋបាលរបស់តុលាការកំពូលក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុគណបក្សនយោបាយនៅមានកំរិត។

## ករណីសិក្សា៖ ហិរញ្ញវត្ថុគណបក្សនយោបាយ នៅប្រទេសបារាំង

## ហិរញ្ញវត្ថុក្នុងជីវភាពនយោបាយ

### សេចក្ដីផ្ដើម

បារាំងជាប្រទេសប្រជាធិបតេយ្យដ៏ចំណាស់មួយនៅអឺរ៉ុប។ ការកសាងនីតិរដ្ឋនៅសាធារណរដ្ឋមួយនេះ ក៏បានចាប់ផ្ដើមតាំងពីជាងពីរសតវត្សមុនមកម្ល៉េះ។ ជាការពិតណាស់ ការបោះឆ្នោតគឺជាប្រធានបទដ៏សំខាន់មួយនៅគ្រប់សង្គមប្រជាធិបតេយ្យ។ ជាពិសេស គឺនៅដំណាក់កាលមុនការបោះឆ្នោត ដែលបេក្ខជនជាគូប្រជែងនយោបាយទាំងអស់ត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីឲ្យខ្លួនអាចទទួលជោគជ័យលើការបោះឆ្នោត។ ការឃោសនាបោះឆ្នោត ក៏បានក្លាយជាកត្តាកំណត់លទ្ធផលបោះឆ្នោតដ៏សំខាន់មួយ។ ជាក់ស្ដែងនៅរាល់ការបោះឆ្នោតម្ដងៗ បញ្ហានៅក្នុងពេលឃោសនាបោះឆ្នោតតែងតែកើតមានឡើង។ នេះក៏បានបង្ហាញពីឥទ្ធិពលនៃអំណាចសេដ្ឋកិច្ចមកលើនយោបាយផងដែរ។ ហេតុដូច្នេះហើយទើបនីតិវិធីមានរបស់បារាំងត្រូវធ្វើការវិវឌ្ឍន៍ខ្លួន។ ការចាប់ផ្ដើមដំបូង គឺនៅឆ្នាំ១៩៨៨ ១៩៩០ ១៩៩៣ ១៩៩៥ និង២០០៣ ដែលសភាជាតិបានអនុម័តច្បាប់ ស្ដីពីហិរញ្ញវត្ថុនយោបាយ។ ការវិវឌ្ឍន៍កើតមានជាបន្តបន្ទាប់ដែលពាក់ព័ន្ធដល់ការបង្កើតវិធានថ្មីសំរាប់គ្រប់គ្រងការចំណាយ កំឡុងពេលឃោសនាការត្រួតពិនិត្យហិរញ្ញប្បទានជាដើមបេក្ខជនជាដើម។

### ខ្លឹមសារសំខាន់ៗ នៃការបង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយ

ការបង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយ ឈរលើគោលការណ៍សំខាន់មួយចំនួនដូចជា៖

- ការទទួលស្គាល់លក្ខន្តិកៈគតិយុត្តរបស់គណបក្សនយោបាយពីសំណាក់រដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឲ្យក្រុមនយោបាយប្រភេទនេះ អាចទទួលបាននូវហិរញ្ញប្បទានសាធារណៈ។
- ការធានាបាននូវតម្លាភាពក្នុងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ក៏ដូចជារបស់បេក្ខជនដែលអាចចៀសវាងបាននូវហិរញ្ញប្បទានទុច្ចរិត និងឥទ្ធិពលអាក្រក់របស់ពួកអ្នកមានអំណាចសេដ្ឋកិច្ចមកលើអ្នកនយោបាយ។ ដូច្នេះហើយ ទើបចាប់ពីឆ្នាំ១៩៩៥មក ហិរញ្ញប្បទានពីនីតិបុគ្គលពោលគឺបណ្ដាសហគ្រាស ក្រុមហ៊ុនទាំងឡាយត្រូវបានហាមឃាត់។
- ការកម្រិតការចំណាយទៅលើការឃោសនាបោះឆ្នោត ដោយគោរពនូវគោលការណ៍សមភាពរវាងបេក្ខជនឈរឈ្មោះទាំងអស់ដោយមិនប្រកាន់ពីភាពខុសគ្នានៃធនធាន។

- ការរៀបចំនូវហិរញ្ញប្បទានសាធារណៈ ដើម្បីតបស្នងនឹងការហាមឃាត់ហិរញ្ញប្បទានពីសំណាក់ពួកសហគ្រាស។
- ការបង្កើតទណ្ឌកម្មធ្ងន់ធ្ងរ ទៅលើអ្នកដែលប្រព្រឹត្តបទល្មើសបន្លំសន្លឹកឆ្នោត ដែលអាចឈានទៅដល់ការដកហូតសិទ្ធិឈរឈ្មោះបោះឆ្នោតបណ្ដោះអាសន្ន។
- ការគ្រប់គ្រងហិរញ្ញវត្ថុការឃោសនាដោយអាជ្ញាធររដ្ឋបាលឯករាជ្យមួយ។ គួរបញ្ជាក់ផងដែរថា ការងាររៀបចំការបោះឆ្នោតនៅប្រទេសបារាំង គឺត្រូវបានរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដី។
- ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាប់ឆ្នោតទាំងអស់ ក្នុងទិសដៅធ្វើយ៉ាងណា ធានាបានថាអ្នកទាំងនោះពុំបានឆ្លៀតឱកាសពីការទទួលបានតំណែងទាំងនេះ ដើម្បីធ្វើការមានបានតាមរយៈអំពើពុករលួយនានាឡើយ។
- តាមរយៈការដាក់ចេញនូវវិធានគ្រប់គ្រងហិរញ្ញវត្ថុ និងហិរញ្ញប្បទានសាធារណៈនេះ ច្បាប់ក៏បានបង្កើតនូវគោលការណ៍សមភាពរវាងបុរស និងស្ត្រីក្នុងការចូលរួមក្នុងវិស័យនយោបាយផងដែរ។

ក្នុងន័យនេះ តាមរយៈហិរញ្ញប្បទានសាធារណៈ គណបក្សនយោបាយណា ដែលមិនបានគោរព គោលការណ៍ខាងលើ នឹងមិនត្រូវបានទទួលហិរញ្ញប្បទានពីរដ្ឋបានឡើយ។

**ហិរញ្ញប្បទានសាធារណៈ**

ហិរញ្ញប្បទានសាធារណៈ គឺជាការផ្ដល់ជូនពីរដ្ឋនូវថវិកាសំរាប់ទ្រទ្រង់ការចំណាយផ្សេងៗរបស់គណបក្សនយោបាយ។ ហិរញ្ញប្បទាននេះ ត្រូវគណនាផ្អែកទៅតាមលទ្ធផលបោះឆ្នោតកន្លងទៅ។ ថវិកាដែលត្រូវផ្ដល់ឲ្យត្រូវបែងចែកក្រោមពីភាគ។ ភាគទីមួយត្រូវធ្វើការបែងចែកដល់គណបក្សនយោបាយណា ដែលមានបេក្ខជនឈរឈ្មោះក្នុងយ៉ាងតិច៥០មណ្ឌលហើយដែលមានសំលេងគាំទ្រលើសពី១%នៃសំលេងឆ្នោតដែលបានបោះ។ ចំណែកឯភាគទីពីរត្រូវបានបម្រុងទុកសំរាប់គណបក្សដែលមានអាសនៈនៅរដ្ឋសភា។

ហិរញ្ញប្បទានសាធារណៈមួយប្រភេទទៀត គឺសំរាប់ផ្ដល់ដល់បេក្ខជនដែលបានចូលរួមក្នុងការបោះឆ្នោត។ ហិរញ្ញប្បទាននេះ ធ្វើឡើងក្រោមរូបភាពជាសំណងដល់ការចាយវាយកាលពីពេលឃោសនាបោះឆ្នោត។ ក៏ប៉ុន្តែមិនមែនគ្រប់បេក្ខជនដែលបានឈរឈ្មោះទាំងអស់នឹងទទួលបាននូវហិរញ្ញប្បទានទាំងនេះទេ។ បេក្ខជនដែលមានសំលេងគាំទ្រលើសពី៥% នៃសម្លេងឆ្នោតបានបោះទើបអាចទទួលបានការសងពីរដ្ឋមកវិញ។ ម្យ៉ាងទៀត បេក្ខជនក៏ត្រូវគោរពតាមកាតព្វកិច្ចគណនីមួយចំនួន ដើម្បីអាចទទួលបានសំណងមកវិញដែរ។

ទោះជាយ៉ាងណាក្តី ការសងនេះពុំមានលក្ខណៈពេញលេញនោះទេ។ ទឹកប្រាក់ដែលត្រូវសងពីរដ្ឋមិនអាចលើសពី៥០%នៃការកម្រិតសំរាប់ការចំណាយឡើយ ហើយក៏មិនត្រូវលើសពីចំណាយជាក់ស្តែងរបស់បេក្ខជនដែរ។ បានសេចក្តីថា បេក្ខជនដែលបានចំណាយតិចជាងពាក់កណ្តាលនៃការកម្រិតសំរាប់ការចំណាយដោយច្បាប់ ទើបអាចទទួលបានសំណងទាំងស្រុងពីរដ្ឋ ហើយពុំមានករណីផ្សេងពីនេះឡើយ។

## បទប្បញ្ញត្តិសម្រាប់ហិរញ្ញប្បទានឯកជន

ជាទូទៅ ហិរញ្ញប្បទានសាធារណៈ ពិតជាមិនអាចគ្រប់គ្រាន់សំរាប់ទ្រទ្រង់ចំណាយរបស់គណបក្សនយោបាយ ឬបេក្ខជននៅពេលឃោសនារកសំលេងឆ្នោតបានឡើយ។ ដូច្នេះហិរញ្ញប្បទានឯក ជនគឺមានចាំបាច់ដដែល។

ចាប់តាំងពីឆ្នាំ១៩៩៥ មកច្បាប់បានកាតផ្តាច់ទាំងស្រុងនូវហិរញ្ញប្បទាន ដែលបានមកពីនីតិបុគ្គល ពោលគឺពពួកក្រុមហ៊ុន និងសហគ្រាសទាំងឡាយ។

ថ្វីត្បិតតែ រូបវន្តបុគ្គលមិនត្រូវបានហាមឃាត់ពីការធ្វើហិរញ្ញប្បទានយ៉ាងណាក្តី ក៏ការធ្វើអំណោយទៅដល់គណបក្សនយោបាយ ឬបេក្ខជនត្រូវតែស្ថិតក្រោមវិធានមួយដ៏តឹងរឹងផងដែរ។ បទដ្ឋានទាំងនោះមាន ដូចជាការកម្រិតនូវតំលៃនៃអំណោយ (មិនឲ្យលើសពី៤៦០០€សំរាប់បុគ្គលម្នាក់ក្នុងមួយឆ្នាំ) ការតម្រូវឲ្យប្រតិបត្តិមធ្យោបាយមូលប្បទានប័ត្រ (ចំពោះអំណោយដែលមានចំនួនលើសពី១៥០€) កាតព្វកិច្ចត្រូវធ្វើបង្កាន់ដៃសំរាប់ការត្រួតពិនិត្យ ព្រមទាំងការយកពន្ធពីការធ្វើអំណោយ អំណោយផងដែរ។

## កម្រិតការចំណាយសំរាប់ការឃោសនា

ដើម្បីធានានូវសមភាពរវាងបេក្ខជនប្រកួតប្រជែងក្នុងការបោះឆ្នោត ការកម្រិតការចំណាយមួយត្រូវបានដាក់ចេញ។ ការកម្រិតនេះត្រូវធ្វើដោយគិតគូរអំពីចំនួនប្រជាជនក្នុងមណ្ឌល ក៏ដូចជាតំលៃសំភារៈទូទៅផងដែរ។ ដូច្នេះឃើញថា ការកម្រិតនេះមានលក្ខណៈបត់បែនបានទៅតាមកត្តាទាំងអស់នេះផងដែរ។

ដើម្បីរកឲ្យឃើញថា ការចំណាយសំរាប់ការឃោសនាមួយត្រូវកម្រិតត្រឹមណា គេត្រូវយកទឹកប្រាក់ ៣៨០០€ បូកនឹងផលគុណនៃចំនួនប្រជាជនសរុបក្នុងមណ្ឌល នឹង០,១៥€ ។ ចំនួនដែលរកឃើញនេះ នឹងត្រូវយកទៅគុណនឹងមេគុណមួយ។ រូបមន្តដែលត្រូវយកមកគណនាត្រូវបានកំណត់ដោយច្បាប់។ ក៏ប៉ុន្តែមេគុណដែលត្រូវយកគុណបន្ថែមនឹងចំនួនរកឃើញ អាចមានការប្រែប្រួល។ ការប្រែប្រួលនេះគឺត្រូវធ្វើឡើងដោយបទបញ្ជានៃអំណាចនីតិប្រតិបត្តិ។ ជាឧទាហរណ៍ មេគុណនេះ

បានប្រែប្រួលពី ១,១២មកដល់១,២៦ហើយនៅឆ្នាំ២០០៨ (តាមរយៈក្រិត្យលេខ ២០០៨-១៣០០)

## ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការឃោសនា

រាល់ចំណូល និងចំណាយសំរាប់ការឃោសនាបោះឆ្នោត ត្រូវប្រមូលផ្តុំក្នុងគណនីទោលមួយ។ បេក្ខជនមិនមានសិទ្ធិ ក្នុងការចាត់ចែងគណនីសំរាប់ការឃោសនារបស់ខ្លួនបានឡើយ។ បេក្ខជនឈរឈ្មោះមានកាតព្វកិច្ច ត្រូវតែងតាំងតំណាងហេរញ្ញិកមួយសំរាប់គ្រប់គ្រងគណនីរបស់ខ្លួន។ តំណាងហិរញ្ញិកនេះអាចជារូបវន្តបុគ្គលដែលមានសមត្ថភាព ឬជាសមាគមហិរញ្ញវត្ថុនយោបាយ។

ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការឃោសនា ត្រូវធានាដោយអាជ្ញាធររដ្ឋបាលឯករាជ្យមួយ។ គណៈកម្មការជាតិគណនីបោះឆ្នោត និងហិរញ្ញវត្ថុនយោបាយ ត្រូវបានបង្កើតឡើងសំរាប់ត្រួតពិនិត្យគណនីរបស់បេក្ខជនកំឡុងពេលឃោសនាបោះឆ្នោត។ ស្ថាប័ននេះមានសិទ្ធិ និងអំណាចក្នុងការត្រួតពិនិត្យគណនីរបស់បេក្ខជន អាចទទួលយកបញ្ជូនត្រឡប់ទៅវិញដើម្បីកែសម្រួល ឬច្រានចោលតែម្តង។ គណនីណាដែលត្រូវបានច្រានចោល គឺមិនអាចទទួលបានសំណងពីរដ្ឋវិញបានឡើយ។ ប្រសិនបើរកឃើញភាពមិនប្រក្រតី គណៈកម្មការនេះមានសិទ្ធិប្តឹងទៅស្ថាប័នអយ្យការចំពោះរឿងព្រហ្មទណ្ឌ។ ក្រុមប្រឹក្សាធម្មនុញ្ញ ក៏មានភារៈទទួលពាក្យបណ្តឹងពីគណៈកម្មាធិការជាតិគណនីបោះឆ្នោត និងហិរញ្ញវត្ថុនយោបាយផងដែរ។ តាមរយៈនីតិវិធីនេះ ថៅក្រមធម្មនុញ្ញអាចប្រកាសដកហូតសិទ្ធិឈរឈ្មោះបោះឆ្នោតពីបេក្ខជនជាប់ចោទផងដែរ។

## ករណីសិក្សា៖ ហិរញ្ញវត្ថុគណបក្សនយោបាយនៅប្រទេសកាណាដា

គោលការណ៍តម្លាភាពយុត្តិធ៌ម និងការចូលរួម គឺជាមូលដ្ឋានគ្រឹះនៃដំណើរការនៃការបោះឆ្នោតសម័យទំនើប។ ប្រវត្តិនៃផ្តល់ហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោតនៅប្រទេសកាណាដា និងការធ្វើកំណែទម្រង់នៅពេលថ្មីៗនេះ បានបង្ហាញពីនិន្នាការមួយឆ្ពោះទៅរកតម្លាភាពធានានូវសមភាព និងលើកកម្ពស់នៃការចូលរួម។ និន្នាការទាំងនេះ ជាភស្តុតាងនៅក្នុងមូលដ្ឋានគ្រឹះនៃរបបហិរញ្ញវត្ថុបោះឆ្នោតយ៉ាងច្រើននៅក្នុងប្រទេសកាណាដាដែលមានដូចជា៖ ការចុះឈ្មោះនៃអ្នកចូលរួមក្នុងការបោះឆ្នោត ដែនកំណត់ក្នុងការចំណាយពេលបោះឆ្នោត និងការកំរិតទៅលើប្រភពនៃការបរិច្ចាគ ការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុបញ្ញត្តិទៅលើការផ្សព្វផ្សាយ និងការជួយផ្តល់មូលនិធិពីរដ្ឋនៅក្នុងដំណើរការបោះឆ្នោត។

របបហិរញ្ញវត្ថុនៃការបោះឆ្នោតទំនើបលើកដំបូងបំផុតនៅប្រទេសកាណាដា កើតមានឡើងនៅឆ្នាំ១៩៦៣នៅក្នុងទីក្រុងកេប៊ិច។ នៅក្នុងឆ្នាំនោះ ច្បាប់បោះឆ្នោតនៃទីក្រុងកេប៊ិចត្រូវបានធ្វើវិសោធកម្ម ដែលបញ្ចូលដែនកំណត់ទៅក្នុងការចំណាយសម្រាប់គណបក្សនយោបាយ និងបេក្ខជនតម្រូវឲ្យបេក្ខជនមានភ្នាក់ងារជាផ្លូវការមួយ ហើយចាប់ណែនាំនូវសំណងវិញមួយចំណែក ក្នុងការចំណាយពេលបោះឆ្នោតទៅឲ្យបេក្ខជនវិញ។

### បរិបទនៅពេលបច្ចុប្បន្ន

បរិបទពេលបច្ចុប្បន្នសម្រាប់កំណែទម្រង់បទប្បញ្ញត្តហិរញ្ញវត្ថុក្នុងការបោះឆ្នោត គឺបណ្តាលមកពីព្រឹត្តិការណ៍ពីរ។ ព្រឹត្តិការណ៍ទីមួយៈ គឺការអនុម័ត*ធម្មនុញ្ញប្រទេសកាណាដាស្តីពីសិទ្ធិ និងសេរីភាព*នៅឆ្នាំ១៩៨២។ ធម្មនុញ្ញនេះ បានចែងពីសេរីភាពជាមូលដ្ឋានគ្រឹះ(ជំពូកទីពីររាប់បញ្ចូលទាំងសេរីភាពនៃការបញ្ចេញមតិ និងសមាគម) និងសេរីភាពប្រជាធិបតេយ្យ (ជំពូកទីបី) ដែលរាប់បញ្ចូលទាំងសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត។ ចាប់តាំងពីឆ្នាំ១៩៨២ មានការកើនឡើងយ៉ាងខ្លាំងនៃជម្លោះទាក់ទងទៅនឹងបញ្ហាការបោះឆ្នោត និងការផ្តល់ហិរញ្ញវត្ថុពេលបោះឆ្នោត។

ព្រឹត្តិការណ៍ទីពីរៈ *គឺគណៈកម្មការពិសេស (Royal Commission) នៃកំណែទម្រង់ការបោះឆ្នោត និងការផ្តល់ហិរញ្ញវត្ថុគណបក្សនយោបាយក្នុងឆ្នាំ១៩៩២ បានបង្ហាញនូវរបាយការណ៍បួនភាគដែលមានអនុសាសន៍ប្រហែលជា៥០០អនុសាសន៍ និងបានបោះពុម្ពនូវការសិក្សាស្រាវជ្រាវចំនួន២៣ភាគរាប់ បញ្ចូលទាំងការស្រាវជ្រាវចំនួន៥ ទាក់ទងទៅនឹងការផ្តល់ហិរញ្ញវត្ថុពេលបោះឆ្នោត។*

### ការហាមប្រាមទៅលើការបរិច្ចាគទៅឲ្យគណបក្សនយោបាយ

ច្បាប់ ស្តីពីការផ្តល់ហិរញ្ញវត្ថុអោយគណបក្សនយោបាយនៅប្រទេសកាណាដា អនុញ្ញាតឲ្យតែប្រជាជនកាណាដា និងប្រជាពលរដ្ឋអចិន្ត្រៃយ៍តែប៉ុណ្ណោះ ដែលអាចធ្វើការបរិច្ចាគមកឲ្យគណបក្សនយោបាយ និងបេក្ខជន។ សាជីវកម្មសហជីពពាណិជ្ជកម្ម និងសមាគមមិនត្រូវបានអនុញ្ញាតឲ្យធ្វើ

ការបរិច្ចាគទៅឲ្យគណបក្សនយោបាយ និងបេក្ខជនបានទេ តែពួកគេអាចធ្វើការបរិច្ចាគបានដោយមិនឲ្យលើសពី$១០០០ជាចំនួនសរុប។ ចំណែកប្រជាជនក្នុងម្នាក់ អាចបរិច្ចាគបានត្រឹមតែ$១០០០០តែប៉ុណ្ណោះក្នុងមួយឆ្នាំសម្រាប់គណបក្សនិមួយៗ។

**ការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ**

ដើម្បីធានានូវតម្លាភាព និងការគោរពទៅតាមច្បាប់ ស្តីពីការផ្តល់ហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោតគណបក្សនយោបាយ និងបេក្ខជនត្រូវបានតម្រូវឲ្យបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដែលមានចំណូល និងចំណាយទៅប្រធាននៃមន្ត្រីបោះឆ្នោត (Chief Electoral Officer) ឬគណៈកម្មការ ស្តីពីការផ្តល់ហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោត ក្នុងរយៈពេលមួយដែលច្បាប់បានកំណត់។ គោលការណ៍នេះ ត្រូវបានគេបញ្ចូលទៅក្នុងច្បាប់ ស្តីពីការផ្តល់ហិរញ្ញវត្ថុពេលបោះឆ្នោតស្ទើរតែគ្រប់តំបន់ទាំងអស់នៅក្នុងប្រទេសកាណាដា ដោយឈរនៅលើគោលការណ៍ថា សាធារណជនដែលជាអ្នកចូលរួមបរិច្ចាគជូនគណបក្សនយោបាយនោះក៏មានសិទ្ធិដឹង និងតាមដាន ថាតើហិរញ្ញវត្ថុនោះត្រូវបានចំណាយដោយរបៀបយ៉ាងដូចម្តេច និងនៅទីណាខ្លះ? ហើយអ្នកណាខ្លះបានជួយផ្តល់ហិរញ្ញវត្ថុឲ្យទៅគណបក្សនយោបាយ និងបេក្ខជនធ្វើសកម្មភាពឃោសនាខ្លះ?

ហិរញ្ញវត្ថុឃោសនាបោះឆ្នោតសហព័ន្ធនៅប្រទេសកាណាដា ត្រូវបានចែងដោយច្បាប់ ស្តីពីការបោះឆ្នោតនៅកាណាដាឆ្នាំ២០០២ ច្បាប់ ស្តីពីពន្ធទៅលើប្រាក់ចំណូល និងច្បាប់ ស្តីពីគណនេយ្យភាពសហព័ន្ធឆ្នាំ២០០៦។ នៅឆ្នាំ២០០៣ ច្បាប់បោះឆ្នោតកាណាដាត្រូវបានធ្វើវិសោធនកម្ម ដើម្បីបង្កើននូវតម្លាភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និងបេក្ខជន។

**ដែនកំណត់ក្នុងការបរិច្ចាគខាងនយោបាយ**

សហជីពការងារ និងសាជីវកម្មត្រូវបានហាមប្រាមក្នុងការបរិច្ចាគទៅឲ្យគណបក្សនយោបាយ និងបេក្ខជន ហើយងាកមកអនុវត្តនូវបទបញ្ញត្តិថ្មី ស្តីពីការផ្តល់មូលនិធិពីរដ្ឋទៅឲ្យគណបក្សនយោបាយ។

មានតែប្រជាពលរដ្ឋដែលមានសញ្ជាតិកាណាដា និងប្រជាពលរដ្ឋដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសកាណាដាប៉ុណ្ណោះ អាចធ្វើការបរិច្ចាគជូនគណបក្សនយោបាយ។ ហើយប្រជាពលរដ្ឋម្នាក់ៗ ត្រូវបានកំណត់ឲ្យធ្វើការបរិច្ចាគត្រឹមតែ$១១០០ដុល្លារប៉ុណ្ណោះជាប្រចាំឆ្នាំ ហើយចំនួននេះអាចត្រូវបានសម្រួបតាមអតិផរណា។

**ការផ្តល់មូលនិធិពីរដ្ឋមកគណបក្សនយោបាយ**

**ដែនកំណត់ក្នុងការចំណាយសម្រាប់ការបោះឆ្នោត**

ច្បាប់ប្រទេសកាណាដា បានដាក់ដែនកំណត់ក្នុងការចំណាយទៅលើគណបក្សនយោបាយ បេក្ខជន និងអ្នកត្រូវបានគេតែងតាំងក្នុងការប្រកួតប្រជែងក្នុងពេលបោះឆ្នោត។ ដែនកំណត់ គឺផ្អែកទៅលើចំនួនអ្នកបោះឆ្នោត និងដង់ស៊ីតេចំនួនប្រជាជននៃមណ្ឌលបោះឆ្នោតដែលបេក្ខជនឈរ

ឈ្មោះ ដោយគុណនិងមេគុណ$០.៧០នៃចំនួនឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃមណ្ឌលបោះឆ្នោត ដែលមានបេក្ខជនរបស់គណបក្សឈរឈ្មោះនៅទីនោះ។

ជាមធ្យមទូទាំង ប្រទេសកាណាដា ការចំណាយរបស់បេក្ខជន គឺនៅចន្លោះពី$៨៥០០០ទៅ $៩០០០០។

## តម្លាភាពសម្រាប់សាធារណជន

បេក្ខជនទាំងអស់ ត្រូវបញ្ជូននូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលបានឆ្លងកាត់ការពិនិត្យ (audit) ហើយមកកាន់ប្រធានមន្ត្រីបោះឆ្នោត (Chief Electoral Officer )ក្នុងកំឡុងពេល៤ខែ បន្ទាប់ពីថ្ងៃបោះឆ្នោត។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះ បេក្ខជនត្រូវតែបង្ហាញនូវរាល់ការចំណាយសម្រាប់ពេលឃោសនាបោះឆ្នោតចំនួនសរុបនៃអំណោយ ឬការបរិច្ចាគដែលទទួលបាន ឈ្មោះអ្នកឲ្យ អសយដ្ឋាន និងកាលបរិច្ឆេទនៃការទទួលអំណោយសម្រាប់អ្នកបរិច្ចាគណាដែលបានបរិច្ចាគលើសពី$២០០។

គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ក៏បានតម្រូវដោយច្បាប់ផងដែរ ឲ្យបញ្ជូននូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលបានឆ្លងកាត់ការពិនិត្យ រួចហើយបញ្ជូនមកប្រធានមន្ត្រីបោះឆ្នោត ក្នុងកំឡុងពេល៦ខែបន្ទាប់ពីថ្ងៃបោះឆ្នោត។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះ បេក្ខជនត្រូវតែបង្ហាញនូវរាល់ការចំណាយសម្រាប់ពេលឃោសនាបោះឆ្នោតចំនួនសរុបនៃអំណោយ ឬការបរិច្ចាគដែលទទួលបាន ឈ្មោះអ្នកឲ្យអសយដ្ឋាន និងកាលបរិច្ឆេទនៃការទទួលអំណោយសម្រាប់អ្នកបរិច្ចាគណាដែលបានបរិច្ចាគលើសពី$២០០។

របាយការណ៍សង្ខេប ស្តីពីការចំណាយ និងចំណូលរបស់គណបក្សនយោបាយ និងបេក្ខជននៅពេលឃោសនាបោះឆ្នោត និងត្រូវបោះពុម្ពដោយប្រធានមន្ត្រីបោះឆ្នោត សម្រាប់ការតាមដានត្រួតពិនត្យពីសាធារណជន។

## អ្នកពង្រឹងនឹងអនុវត្តច្បាប់ហិរញ្ញវត្ថុគណបក្សនយោបាយនៅកាណាដា

ស្ថាប័នសំខាន់ ដែលទទួលខុសត្រូវតាមដានការអនុវត្តន៍ច្បាប់របស់គណបក្សនយោបាយ និងបេក្ខជន គឺស្ថាប័នឈ្មោះការបោះឆ្នោតនៅកាណាដា (Elections Canada)។ ស្ថាប័ននេះដឹកនាំដោយប្រធានមន្ត្រីបោះឆ្នោត ហើយរាយការណ៍ដោយផ្ទាល់ទៅសភាទាក់ទងទៅនឹងការប្រតិបត្តិការរបស់ប្រព័ន្ធបោះឆ្នោតសហព័ន្ធ។ ស្ថាប័នបោះឆ្នោតកាណាដាចាត់តាំងមន្ត្រីបោះឆ្នោតឯករាជ្យដែលមានឈ្មោះថា គណៈអភិបាលនៃការបោះឆ្នោតកាណាដា(Commissioner of Canada Election) ដែលមានភារកិច្ចធានាថា បញ្ញត្តិនៃច្បាប់បោះឆ្នោតកាណាដា ត្រូវបានពង្រឹង និងអនុវត្ត គណៈអភិបាលនេះ ក៏មានអំណាចបញ្ជាឲ្យបើកការស៊ើបអង្កេតទៅលើកាល្មើសច្បាប់ ស្តីពីហិរញ្ញវត្ថុគណបក្សពេលឃោសនា និងអនុវត្តការសម្រេចចិត្តរបស់តុលាការ។

## ទណ្ឌកម្មចំពោះការល្មើសច្បាប់

ប្រសិនបើ បេក្ខជនណាម្នាក់ត្រូវបានកាត់ទោសដោយតុលាការពីបទបានរំលោភទៅលើច្បាប់

ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត បេក្ខជននោះនឹងអាចផ្តន្ទាទោសជាការផាកពិន័យផង និងជាប់ពន្ធនាគារផង។ នៅក្នុងច្បាប់ស្តីពីការបោះឆ្នោតនៅកាណាដាតុលាការអាចដាក់ទោសបន្ថែមទៀតដែរដូចជា៖

- សំណងនៃការខូចខាត
- ការលប់ឈ្មោះ ឬធ្វើការជំរះបញ្ជីទ្រព្យសម្បត្តិនៃគណបក្សនយោបាយ
- អាចត្រូវបានពិន័យគុណនិងប្រាំដង ចំពោះការឃោសនាបោះឆ្នោតដែលបានចំណាយលើសដែនកំណត់។

## ករណីសិក្សា ៖ ហិរញ្ញវត្ថុគណបក្សនយោបាយ នៅសហរដ្ឋអាមេរិក

ប្រព័ន្ធច្បាប់ប្បញ្ញត្តិហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោតនៅអាមេរិក គឺផ្តោតយ៉ាងសំខាន់ទៅលើការចង់ឲ្យមានការដាក់បង្ហាញជាសាធារណៈឲ្យបានពេញលេញ និងត្រឹមត្រូវនៃការចំណាយ និងមូលនិធិដែលរកបានដោយបេក្ខជនសម្រាប់តំណែងនយោបាយ និងគណៈកម្មកាហិរញ្ញវត្ថុរបស់ពួកគេ ដែលមានគណបក្សនយោបាយ និងគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយឯករាជ្យ។ នៅក្នុងប្រពន្ធ័នេះ មានបញ្ហាជាច្រើនបានកើតមានឡើងនៅក្នុងកំឡុងពេល២០ឆ្នាំចុងក្រោយមកនេះ ដែលភាគច្រើនទាក់ទងជាមួយនិងការផ្តល់មូលនិធិសម្រាប់ឃោសនាជាប្រាក់ទុន(Soft money) និងការផ្សព្វផ្សាយការតស៊ូមតិ។ រាល់បញ្ហាទាំងនេះ បាននាំឲ្យមានការបើកស៊ើបអង្កេតជា បន្តបន្ទាប់ភ្លាមៗ ទៅក្នុងសកម្មភាពនៃគណបក្សនយោបាយសំខាន់ៗទាំងពីរ និងកំណែទម្រង់ បទប្បញ្ញត្តិថ្មីនៅក្នុងសភាថ្នាក់សហពន្ធ័ និងថ្នាក់រដ្ឋ។

### 1) ប្រពន្ធ័ដំណើរការនៃប្បញ្ញត្តិហិរញ្ញវត្ថុពេលឃោសនា

នៅប្រទេសអាមេរិក មានការអភិវឌ្ឍន៍ប្រពន្ធ័ស្ថាប័នសម្រាប់គ្រប់គ្រងទៅលើការផ្តល់នូវមូលនិធិយ៉ាងល្អប្រសើរនៃយុទ្ធនាការឃោសនាបោះឆ្នោតសហពន្ធ័។ ការឃោសនាបោះឆ្នោតនៃរដ្ឋខុសៗគ្នា និងនៅតាមថ្នាក់តំបន់ត្រូវបានប្រព្រឹត្តទៅដោយអនុលោមទៅតាមច្បាប់របស់រដ្ឋ។

មូលដ្ឋានច្បាប់គ្រឹះ ដែលប្បញ្ញត្តិពីហិរញ្ញវត្ថុឃោសនាបោះឆ្នោតសហពន្ធ័នៅប្រទេសអាមេរិក គឺច្បាប់ស្តីពី*យុទ្ធនាការឃោសនាបោះឆ្នោតសហពន្ធ័ឆ្នាំ១៩៧២*។ ដោយអនុលោមទៅតាមការធ្វើវិសោធនកម្មនៅឆ្នាំ១៩៧៤នៃច្បាប់នេះ ស្ថាប័នឯករាជ្យមួយត្រូវបានបង្កើតឡើង គឺគណៈកម្មការបោះឆ្នោតសហពន្ធ័ (Federal Election Commission) ដែលមានគោលបំណងពង្រឹងនូវការសង្កេតការណ៍នៃច្បាប់បោះឆ្នោតសហពន្ធ័ និងជាជំនួយក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរដ្ឋបាលនៃកម្មវិធីការផ្តល់ហិរញ្ញវត្ថុពីរដ្ឋ។

បន្ទាប់ពីតុលាការជាន់ខ្ពស់អាមេរិក បានពិចារណារឿងក្តីមួយរួចមក (Buckley v. Valeo) នៅឆ្នាំ១៩៧៦សភាអាមេរិកបានផ្តើមនូវវិសោធនកម្មមួយនៃច្បាប់នេះដែលបានអនុម័តនៅឆ្នាំ១៩៧៩។ ការធ្វើវិសោធនទាំងនោះ ត្រូវបានអនុម័តដើម្បីកែលម្អនូវដំណើរការធ្វើរបាយការណ៍ និងបង្កើននូវតួនាទីនៃគណបក្សនយោបាយ។ ច្បាប់នេះបានផ្តល់ឲ្យមាន៖

1. ការបោះពុម្ពផ្សាយនៃរបាយការណ៍ចំណូល និងចំណាយទៅឲ្យរដ្ឋបាលឃោសនាបោះឆ្នោតសហពន្ធ័។

2. ការដាក់ដែនកំណត់ និងហាមប្រាមនៃការបង់ថ្លៃ និងចំណាយសម្រាប់រដ្ឋបាលបោះឆ្នោតសហពន្ធ័។

3. ហិរញ្ញវត្ថុពីរដ្ឋ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៃការបោះឆ្នោតប្រធានាធិបតីអាមេរិក។

ដោយអនុលោមទៅតាមច្បាប់ គណៈកម្មាធិការរបស់បេក្ខជន គណៈកម្មាធិការរបស់គណបក្សនយោបាយ និងគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយ ត្រូវបានតម្រូវឲ្យបញ្ជូននូវរបាយ ការណ៍តាមរយៈពេលមួយ អំពីការទទួល និងការចំណាយហិរញ្ញវត្ថុ។ ឧទាហរណ៍បេក្ខជនទាំងអស់ត្រូវបានតម្រូវឲ្យផ្តល់នូវបញ្ជីឈ្មោះនៃគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយ និងគណៈកម្មាធិការបក្ស នីតិបុគ្គល និងឯកជនទាំងអស់ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ពួកគេលើសពី$២០០ក្នុង១ឆ្នាំ។

ដែនកំណត់សម្រាប់ចំនួននៃការបរិច្ចាគដោយស្មគ្រ័ចិត្ត ត្រូវបានបង្កើតឡើងដាច់ដោយឡែកពីគ្នាសម្រាប់បុគ្គលឯកជនគណៈកម្មាធិការនយោបាយ និងគណៈកម្មាធិការនយោបាយដែលគាំទ្របេក្ខជនច្រើននាក់។ ចំនួនទាំងនោះខុសៗគ្នាគឺអាស្រ័យទៅលើ ថាតើការបរិច្ចាគនេះសម្រាប់អ្នកណា? ការបរិច្ចាគពីបុគ្គលឯកជន គឺមិនអាចលើសពីៈ

– $១០០០ដែលផ្តល់ទៅឲ្យបេក្ខជន ឬគណៈកម្មាធិការបេក្ខជនសម្រាប់ការឃោសនាបោះឆ្នោតមួយជុំ។

– $២០០០០ក្នុងកុំឡុងពេល១មួយឆ្នាំប្រតិទិន ដែលផ្តល់ឲ្យគណៈកម្មាធិការនយោបាយដែលបានបង្កើតឡើង និងកំពុងត្រូវបានគេថែរក្សាដោយគណបក្សនយោបាយជាតិខ្លះៗ ហើយមិនមែនរបស់បេក្ខជនទេ។

– $៥០០០ក្នុងកុំឡុងពេល១ឆ្នាំប្រតិទិន ដែលផ្តល់ទៅឲ្យគណៈកម្មាធិការនយោបាយដទៃណាមួយ។

បុគ្គលម្នាក់មិនអាចបរិច្ចាគលើសពី$២៥០០០បានទេ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតក្នុងមួយឆ្នាំប្រតិទិន។

សាជីវកម្មសហជីពពាណិជ្ជកម្មអ្នកធ្វើកិច្ចសន្យាជាមួយរដ្ឋាភិបាលសហពន្ធ័ និងជនបរទេសមិនត្រូវបានអនុញ្ញាតឲ្យធ្វើការបរិច្ចាគ ឬចំណាយជួយបេក្ខជនសហពន្ធ័ទេ។ វិធានការនៃច្បាប់ជាច្រើនដូចជាច្បាប់ស៊ីវិល ច្បាប់រដ្ឋបាល និងច្បាប់ឧក្រិដ្ឋកម្មត្រូវបានយកមកប្រើប្រាស់ដើម្បីពង្រឹងនូវភាពតឹងរឹង ដែលបានដាក់ទៅលើការចូលរួមការបោះឆ្នោត ទាក់ទងទៅនឹងការផ្តល់មូលនិធិ

ឃោសនាបោះឆ្នោតសហពន្ធ័។ វិធានការទាំងនេះត្រូវបានអនុវត្តដោយគណៈកម្មការបោះឆ្នោតសហពន្ធ័ និងក្រសួងយុត្តិធម៌។

2) **ហិរញ្ញវត្ថុឃោសនាក្នុងការជៀសវាងបទប្បញ្ញត្តិដែលមានស្រាប់**

នៅក្នុងការអនុវត្តន៍គណបក្សនយោបាយ និងបេក្ខជនអាចបង្កើនចំនួននៃប្រភពហិរញ្ញវត្ថុរបស់ខ្លួន ហើយទទួលបានការផ្តល់នូវមូលនិធិយ៉ាងច្រើនលើសលប់ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់ពួកគេ។ ពួកគេធ្វើយ៉ាងនេះបានដោយមិនបំពានច្បាប់ទេ គឺគេបានប្រើភាពមានចន្លោះប្រហោងនៅក្នុងច្បាប់ ក្នុងការស្វែងរកនូវមូលនិធិបន្ថែមទៀតដែលអាជ្ញាធរមិនដាក់ទណ្ឌកម្មគេបានទេ។

a) **បញ្ហាលុយទន់** (Soft money)

លុយទន់ គឺជាប្រាក់ដែលរកបាន និងចំណាយនៅក្រៅក្របខណ្ឌដែលបានហាមនៅក្នុងច្បាប់បោះឆ្នោតសហពន្ធ័។ នៅប្រទេសអាមេរិកលុយទន់នេះបានដើរតួនាទីយ៉ាងធំធេងនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតសហពន្ធ័។ តាមច្បាប់ ប្រាក់ទាំងនេះត្រូវបានប្រគល់ទៅឲ្យគណៈកម្មាធិការជាតិនៃគណបក្សនយោបាយ ដែលបានបង្កើតឡើងនៅថ្នាក់រដ្ឋ។ វាមិនមានគោលបំណងសម្រាប់ផ្តល់នូវមូលនិធិក្នុងការយុទ្ធនាការឃោសនាដោយផ្ទាល់ទេ ប៉ុន្តែត្រូវបានប្រើប្រាស់សម្រាប់សេចក្តីត្រូវការរបស់គណបក្ស។ ដូច្នេះ វាអាចបង្កើតឲ្យមានការប្រើប្រាស់ដោយប្រយោលសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ជាទូទៅ លុយទន់នេះត្រូវបានគេប្រើប្រាស់សម្រាប់លើកសរសើរពីគុណសម្បត្តិនៃគណបក្សនយោបាយណាមួយ។

ច្បាប់បានហាមប្រាមសាជីវកម្មធនាគារ និងសហជីពពាណិជ្ជកម្មក្នុងការបរិច្ចាគលុយទៅកាន់មូលនិធិបោះឆ្នោតរបស់បេក្ខជន ហើយធ្វើការបរិច្ចាគដោយឯករាជ្យដើម្បីសម្របសម្រួលការបោះឆ្នោតនៃបេក្ខជនជាក់លាក់ណាមួយ ប៉ុន្តែគ្មានអ្វីហាមប្រាមពួកគេមិនឲ្យដាក់លុយមួយចំនួនធំសម្រាប់ការប្រើប្រាស់របស់គណបក្សឡើយ។

b) **ការផ្សព្វផ្សាយមុនពេលការបោះឆ្នោត**

ពេលបោះឆ្នោតសភាសហពន្ធ័នៅឆ្នាំ១៩៩៦ បានបង្ហាញឲ្យឃើញពីវិធីមួយទៀត ដែលមិនបានបញ្ញត្តិនៅក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុឃោសនាពេលបោះឆ្នោត ដែលវិធីនោះបានប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំង ទៅលើប្រពន្ធ័ទាំងមូលនៃវិធានការគ្រប់គ្រងហិរញ្ញវត្ថុ គឺបញ្ហាផ្សព្វផ្សាយការតស៊ូមតិ។ យោងទៅតាមការអនុវត្តន៍នេះបុគ្គល និងក្រុមឯករាជ្យដែលបានគាំទ្រក្នុងរឿងនយោបាយណាមួយ អាចចំណាយលុយទៅលើការផ្សព្វផ្សាយរឿងនយោបាយរបស់ពួកគេតាមTV

និងសារព័តមាន និងតាមខិត្តប័ណ្ណផ្សេងៗ។ លុយទាំងនេះមិនបានផ្តល់ទៅឲ្យគណបក្សនយោបាយទេ ហើយក៏មិននៅក្រោមច្បាប់គ្រប់គ្រងរបស់សហពន្ធ័ដែរ។ យោងតាមរបាយការណ៍ស្រាវជ្រាវពីឆ្នាំ១៩៩៥ដល់ឆ្នាំ១៩៩៦ មានក្រុមចំនួន២០ក្នុងចំណោម៣០ក្រុម បានចំណាយមិនតិចជាង $៥០លាន ឬអាច$១០០លានទៅលើបញ្ហាទាំងនោះ។ សកម្មភាពនៃក្រុមទាំងនោះ ត្រូវបានសម្របសម្រួលដោយអ្នកគាំទ្របេក្ខជន។

# ឧបសម្ព័នទី១

## គំរូនៃការបង្កើតច្បាប់ស្តីពី ហិរញ្ញវត្ថុឃោសនានយោបាយ

(Law on Political Campaign Finance)

**ជំពូកទី១. ការពន្យល់ពាក្យ**

- គណៈកម្មការត្រួតពិនិត្យហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោត
- ការផ្តល់ធនធានជូនគណបក្សនយោបាយ
- មូលនិធិសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត
- ការចំណាយសម្រាប់ពេលឃោសនាបោះឆ្នោត
- ធនធានរបស់រដ្ឋ

**ជំពូកទី២. ការចុះបញ្ជីនៃទ្រព្យសម្បត្តិរបស់បេក្ខជន**

- បេក្ខជនត្រូវផ្តល់អោយគណៈកម្មាធិការត្រួតពិនិត្យហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោតមុនពេលចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត និងក្រោយពេលឃោសនាបបោះឆ្នោត

**ជំពូកទី៣.ប្រភពមូលនិធិសម្រាប់គាំទ្រគណបក្សនយោបាយពេលឃោសនាបោះឆ្នោត**

- ការផ្តល់ជូនគណបក្សនយោបាយពីផ្នែកឯកជននិងរដ្ឋ
- គោលការណ៍ទូរទៅក្នុងការផ្តល់មូលនិធិជូនគណបក្សនយោបាយ
- ហាមប្រាមនូវមូលនិធិនិងអំណោយផ្សេងៗ
- ការដាក់កំណត់ទៅលើការបរិច្ចាកពីផ្នែកឯកជននិងប្រជាពលរដ្ឋ

**ជំពូកទី៤.ការចុះបញ្ជីរនូវមូលនិធិដែលទទួលបានសម្រាប់ការឃោសនាបោះឆ្នោត**

- ត្រូវចុះបញ្ជីរនូវរាល់អ្វីៗទាំងអស់ដែលទទួលបាន(ប្រាក់,មិនមែនជាប្រាក់,សេវា..)
- ត្រូវចេញវិក័យបត្តមួយជូនទៅអ្នកដែលបានផ្តល់មូលនិធិអោយគណបក្សនយោបាយ

**ជំពូកទី៥.ការចុះបញ្ជីរពេលចំណាយក្នុងការឃោសនាបោះឆ្នោត**

- ការដាក់ដែនកំណត់ទៅលើការចំណាយពេលឃោសនាបោះឆ្នោត
- រាល់ការចំណាយទាំងអស់ពេលឃោសនាត្រូវតែចុះទៅក្នុងបញ្ជីរចំណាយ
- កត់ត្រាអំពីប្រភេទចំណាយ,កាលបរិច្ឆេតនិងឈ្មោះអ្នកដែលបានទទួលកាចំណាយ និងការរក្សាទុកនូវ

វិក័យបត្រទាំងអស់នោះ

## ជំពូកទី៦.គណនេយ្យ

- ការដាក់ដែនកំណត់អប្បរមាសម្រាប់ការផ្តល់មូលនិធិដែលត្រូវដាក់ចូលដោយផ្ទាល់ទៅក្នុងគណនេយ្យ
- ការដាក់ដែនកំណត់អប្បរមាសម្រាប់ការចំណាយដោយធ្វើការទូទាត់ដោយផ្ទាល់ពីគណនេយ្យ

## ជំពូកទី៧.ភ្នាក់ងារហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

- លក្ខណ:សម្បត្តិរបស់ភ្នាក់ងារហិរញ្ញវត្ថុរបស់គណបក្សនយោបាយ
- កាតព្វកិច្ចរបស់ភ្នាក់ងារហិរញ្ញវត្ថុរបស់គណបក្សនយោបាយដើម្បីធានាថាគណបក្សគោរពទៅតាមច្បាប់ហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត

## ជំពូកទី៨.របាយការណ៍ចំណូលនិងចំណាយ

- ការថែរក្សាទុកនូវរាល់ឯកសានិងវិក័យបត្រចំណូលនិងចំណាយក្នុងពេលឃោសនា
- ការធ្វើរបាយការណ៍
- ថេរវេលាសម្រាប់ធ្វើរបាយការណ៍ជូនទៅស្ថាប័នសម្រាប់ត្រួតពិនិត្យ
- ការឆ្លើយតបរបស់ស្ថាប័នត្រួតពិនិត្រ

## ជំពូកទី៩.ការបង្កើតគណ:កម្មការឯករាជ្យក្នុងការតាមដាននិងពិនិត្យមើលការគោរពច្បាប់របស់គណបក្សនយោបាយ

ការបង្កើតស្ថាប័នឯករាជ្យតាមដានការគោរពច្បាប់របស់គណបក្សនយោបាយ

- នីតិវិធីនៃការត្រួតពិនិត្យរបស់ស្ថាប័ន
- ថេរវេលាសម្រាប់នីតិវិធីនិមួយៗ
- សវនការ
- ការប្តឹងតវ៉ាលើសេចក្តីសម្រេច
- ការចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

## ជំពូកទី១០.ទោសប្បញ្ញត្ត

- ការមិនអនុវត្តតាមកាតព្វកិច្ចគណនេយ្យ ឬមិនវេលាកំណត់
- ការចំណាយហួសដែនកំណត់
- ការធ្វើរបាយការណ៍ក្លែងក្លាយ
- ការឃុបឃិតពីមន្ត្រីស្ថាប័ន

# ឧបសម្ព័ន្ធទី ២

# បញ្ជីឈ្មោះអ្នកចូលរួមនៅក្នុងសិក្ខាសាលា ស្ដីពីហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត

## ១.តំណាងគណបក្សនយោបាយ

- គណបក្សប្រជាជនកម្ពុជា
- គណបក្សសមរង្ស៊ី
- គណបក្សសិទ្ធិមនុស្ស
- គណបក្សហ៊្វុនស៊ិនប៉ិច
- គណបក្សជាតិនិយម

## ២.តំណាងស្ថាប័ន,ស្ថានទូត និងអង្គការជាតិនិងអន្តរជាតិ

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- រាជបណ្ឌិតសភានៃកម្ពុជា
- IFES
- CDP
- ADHOC
- The National Democratic Institute (NDI)
- Cambodia Center for Human Rights (CCHR)
- Cambodia-Canada Legislative Support Project (CCLSP)
- NICFEC
- Cambodia Development Resource Institute
- **US Embassy**
- **French Embassy**
- Norwegian People's Aid
- Forum Syd
- SIDA
- IRI
- Trocaire
- Delegation of The European Commission to The Kingdom of Cambodia
- STAR KAMPUCHEA
- Khmer Institute of Democracy (KID)
- Youth Resource Development Program (YRDP)
- Khmer Kampuchea Krom Human Right Association (KKKHRA)
- Legal Aid of Cambodia (LAC)
- Community Legal Education Center
- The Khmer Kampuchea Krom Community
- NGO Forum
- Center for Social Development

- UNDP-Cambodia
- YRDP
- LICADHO
- CITA
- CHHRAC
- Pact Cambodia
- PDP

**៣.តំណាងអ្នកសារព័ត៌មាន**

- កាសែតរស្មីកម្ពុជា
- កាសែតកោះសន្តិភាព
- កាសែតកម្ពុជាថ្មី
- The Cambodia Daily
- Phnom Penh Post
- កាសែតខ្មែរអមតៈ
- វិទ្យុអាស៊ីសេរី
- វិទ្យុសម្លេងសហរដ្ឋអាមេរិក
- វិទ្យុបារាំងអន្តរជាតិ
- ទូរទស្សន៍ប៉ុស្តិ៍លេខ៩
- ទូរទស្សន៍CTN

# ឧបសម្ព័ន្ធទី ៣

## ការចុះ និងចាក់ផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយ

អង្គសិក្ខាសាលានេះត្រូវបានចាក់ផ្សាយនៅក្នុងកម្មវិធីព័ត៌មានតាមរយៈ ទូរទស្សន៍ប៉ុស្តិ៍ CTN ប៉ុស្តិ៍ទូរទស្សន៍ជាតិកម្ពុជា (ទទក) និងប៉ុស្តិ៍ទូរទស្សន៍លេខ៩ (ទទ៩)។

### តំណាងរាស្ត្រ គណបក្សទាំង ៥ ជួបគ្នា គាំទ្រ ច្បាប់ហិរញ្ញវត្ថុ

Wednesday, 26 May 2010 19:52 DAP-NEWS

**ភ្នំពេញ:** តំណាងរាស្ត្រគណបក្សទាំង ៥ ដែលមានសំឡេងនៅក្នុងរដ្ឋសភា រួមមានគណបក្សប្រជាជនកម្ពុជា, គណបក្ស សម រង្ស៊ី គណបក្សសិទ្ធិមនុស្ស, គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សជាតិនិយម ( អតីតគណបក្ស នរោត្តម រណឫទ្ធិ ) នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ បានជួបពិភាក្សាគ្នា ដើម្បីគាំទ្រក្នុងការបង្កើតច្បាប់ហិរញ្ញវត្ថុ ដល់បក្សនយោបាយ នៅពេលឃោសនាបោះឆ្នោត ។

ការជួបពិភាក្សាគ្នាគាំទ្រច្បាប់ហិរញ្ញវត្ថុ ខាងលើនេះ ត្រូវបានធ្វើឡើងនៅក្នុងសិក្ខា សាលា ដែលរៀបចំឡើងដោយអង្គឃ្លាំមើល ការបោះឆ្នោតខុមហ្វ្រែល ស្តីពីហិរញ្ញវត្ថុគណ បក្សនយោបាយ ពេលឃោសនាបោះឆ្នោត នៅសណ្ឋាគារអ៊ីមភើរៀល ហ្គាឌិន ក្នុងរាជ ធានីភ្នំពេញ ។

តំណាងរាស្ត្រគណបក្សប្រជាជន និងជា ប្រធានគណ:កម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មជាតិនៃរដ្ឋសភា លោក ជាម យៀប បានបង្ហាញពីការគាំទ្រនៅក្នុង ការជួបពិភាក្សាគ្នា នៅក្នុងសិក្ខាសាលានោះ។

អគ្គលេខាធិការ គណ:កម្មការជាតិរៀប ចំការបោះឆ្នោត បានមានប្រសាសន៍ផងដែរ ថា គណ:កម្មការជាតិរៀបចំការបោះឆ្នោត បានត្រៀមខ្លួនក្នុងការអនុវត្តន៍ច្បាប់ទាំងនេះ ឱ្យមានប្រសិទ្ធភាព ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ អង្គការឃ្លាំមើលការបោះឆ្នោតខុមហ្វ្រែល បានឱ្យដឹងថា ច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញ វត្ថុ របស់គណបក្សនយោបាយនៅពេល ឃោសនាបោះឆ្នោតមានសារ:សំខាន់ ក្នុងការ ជួយកាត់បន្ថយអំពើពុករលួយ ការទិញសន្លឹក ឆ្នោត និងកំណត់នូវការចំណាយថវិការបស់ គណបក្សនយោបាយ នៅពេលបោះឆ្នោត ម្តងៗ ។

សេចក្តីប្រកាសព័ត៌មាន បានបញ្ជាក់ទៀត ថា ច្បាប់នេះក៏បានធានាឱ្យមានការប្រកួត ប្រជែង ដោយយុត្តិធម៌ រវាងគណបក្សដែល មានធនធាន និងគណបក្សដែលមិនសូវមាន ធនធាន ហើយច្បាប់ថ្មីនេះ ក៏ជាកត្តាលិករ មួយ ក្នុងការជំរុញលើកកម្ពស់តម្លាភាព និង គណនេយ្យភាព ដែលមានចែងនៅក្នុងសន្ធិ សញ្ញា របស់អង្គការសហប្រជាជាតិ ប្រឆាំង ទៅនឹងអំពើពុករលួយ ដែលប្រទេសកម្ពុជា ជាប្រទេសហត្ថលេខីមួយផងដែរ នៅក្នុងសន្ធិ សញ្ញានោះ ។

ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់គណ បក្សនយោបាយខាងលើនេះ ក៏បានផ្តល់ជំនឿ ទុកចិត្តទៅដល់ប្រជាពលរដ្ឋ មកលើការដឹក នាំគណបក្សនយោបាយ ដែលប្រកបទៅដោយ លទ្ធិប្រជាធិបតេយ្យ ។

សូមបញ្ជាក់ថា ច្បាប់ស្តីពីគណបក្សនយោ បាយ ដែលត្រូវបានតំណាងរាស្ត្រគណបក្ស ទាំង ៥ ឯកភាពគាំទ្រនោះ ត្រង់មាត្រា ២៨ ចែងថា រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗ គ្នា ដល់គ្រប់គណបក្សនយោបាយសម្រាប់ ប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ។

# Campaign funds discussed

THURSDAY, 27 MAY 2010 15:01 VONG SOKHENG (THE PHNOM PENH POST)

AT least 50 representatives of five political parties met with the election monitoring group Comfrel on Wednesday to discuss the creation of a law that would regulate campaign funding.

Comfrel executive director Koul Panha said that a majority of participants at the meeting supported the proposed law, a draft of which he said would be written by Comfrel in time for elections scheduled for 2012 and 2013.

“We would try to establish a law to make campaign funding transparent, and that would control the revenue and spending of each political party,” he said, and added that a final decision on whether a new law will be drafted has not been made.

The ruling Cambodian People’s Party, the Sam Rainsy Party, the Human Rights Party, Funcinpec and the Nationalist Party were all represented at Wednesday’s meeting.

Koul Panha said the draft law would call on the government to provide equal campaign budgets for all political parties, and that this would help reduce the funding gap between the CPP and opposition parties.

SRP lawmaker Son Chhay said a law regulating campaign spending should be drafted as soon as possible.

“If [we] have that law, it can control the expenses for the election campaigns of political parties during the election, and it could reduce the influence of the ruling party, which has a big campaign budget because it gets a lot of income from private companies,” he said.

HRP President Kem Sokha also said he supported the creation of a new law, and that it could improve transparency and reduce the campaign budget of the CPP.

“I support a law that will give equal budget and equal media access during the election campaigns, and I think that the elections have not been free and fair when there was a lack of control of campaign finances, especially of the ruling party,” he said.

Sokolac Tipor, deputy secretary general of the National Election Committee, said it would be difficult to draft a meaningful law, given that campaigning in one form or another seems to be going on constantly.

“It is difficult to give the definition of a campaign, because individual politicians are going down to their constituencies almost every day to donate to their supporters,” he

said.

“That could be said to be part of a political campaign, or it could not,” Sokolac Tipor added.

Government spokesman Khieu Kanharith could not be reached for comment on Wednesday.

# អ្នកនយោបាយចង់បង្កើតច្បាប់ហិរញ្ញវត្ថុ គណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត

Created *2010-05-26 15:18*
ដោយ លី ម៉េងហួរ(វិទ្យុបារាំងអន្តរជាតិ)
កម្ពុជា
អ្នកនយោបាយ ដែលមានសម្លេងឆ្នោតនៅក្នុងរដ្ឋសភាបានគាំទ្រនិងផ្តួចផ្តើមឲ្យមាន ការបង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយនៅពេលឃោសនា បោះឆ្នោត។ ច្បាប់ថ្មីនេះដើម្បីធានាដល់គណបក្សនយោបាយទាំងអស់ឲ្យធ្វើការ ប្រកួតប្រជែងឃោសនាបោះឆ្នោតដោយស្មើភាព។ ច្បាប់នេះក៏ជាការជម្រុញនិងលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុង សង្គមកម្ពុជាផងដែរ។

ហិរញ្ញវត្ថុ គណបក្សនយោបាយពេលឃោសនាបោះឆ្នោតគឺជាប្រធានបទនៃកិច្ចពិភាក្សាមួយ ដែលរៀបចំដោយអង្គការឃ្លាំមើលការបោះឆ្នោតខុមហ្វ្រែល។

ក្នុងកិច្ចពិភាក្សានៅព្រឹកមិញ សមាជិកសភានិងតំណាងមកពីគណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សជាតិនិយម (អតីតគណបក្ស នរោត្តម រណឫទ្ធិ) បានបង្ហាញជំហរម្តងម្នាក់ៗ ដោយចង់ឲ្យមានការតាក់តែងច្បាប់ថ្មីមួយស្តីពីហិរញ្ញវត្ថុគណបក្ស នយោបាយនៅពេលឃោសនាបោះឆ្នោត។ គណបក្សនយោបាយទាំងនេះ មានសម្លេងភាគតិចក្នុងរដ្ឋសភានីតិកាលទី៤។

តាមអង្គការឃ្លាំមើលការបោះឆ្នោតខុមហ្វ្រែលច្បាប់ស្តីពីហិរញ្ញវត្ថុ របស់គណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោតមានសារៈសំខាន់ក្នុងការជួយ កាត់បន្ថយអំពើពុករលួយ ការទិញសន្លឹកឆ្នោត និងកំណត់នូវការចំណាយថវិការបស់គណបក្សនយោបាយនៅពេលបោះឆ្នោតម្តងៗ

ច្បាប់ថ្មីនេះក៏ដើម្បីធានាឲ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ រវាងគណបក្សដែលមានធនធាននិងគណបក្សដែលមិនសូវមានធនធាន។ ច្បាប់នេះក៏ជាការជម្រុញនិងលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុង សង្គមកម្ពុជាផងដែរ។

តំណាងគណបក្សដែលមានសម្លេងតិចតួចនៅរដ្ឋសភាបានជម្រុយឲ្យមានការ បង្កើតច្បាប់គ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោត ដើម្បីលុបបំបាត់នូវឥទ្ធិពលនៃការផ្តល់ប្រាក់ពីឯកជននិងការរៃ អង្គាសប្រាក់ពីក្រុមហ៊ុន អ្នកជំនួញ និង

អ្នកគាំទ្រ ដើម្បីជួយដល់គណបក្សកាន់អំណាច។

ម្យ៉ាងទៀត តំណាងគណបក្សក្រៅរដ្ឋាភិបាលបានបញ្ជាក់ថា នៅពេលឃោសនាបោះឆ្នោតម្តងៗ គណបក្សកាន់អំណាចមានលទ្ធភាពច្រើនក្នុងការឃោសនា និងទាក់ទាញអ្នកគាំទ្រដោយមានទាំងការផ្តល់ជាអំណោយជាដើម។

ក៏ប៉ុន្តែលោក ជាម យៀប សមាជិកសភានិងជាតំណាងគណបក្សប្រជាជនកម្ពុជាបានបញ្ជាក់នៅក្នុង កិច្ចពិភាក្សាថា គណបក្សកាន់អំណាចមួយនេះ មានថវិកាដ៏ច្រើនលើសលប់ គឺបានមកពីវិភាគទានសមាជិកគណបក្សជាង៥លាន នាក់អំណោយរបស់សប្បុរសជនកជនជាឧកញ៉ា និងក្រុមហ៊ុន រួមទាំងអចលនៈទ្រព្យជាច្រើនផ្សេងទៀត។ យ៉ាងណាក៏ដោយ អង្គការខុមហ្វ្រែលបានលើកឡើងថា នៅកម្ពុជាអ្នកឧកញ៉ា ពាណិជ្ជករ និងអ្នកជំនួញធំៗ បានចូលរួមផ្តល់ថវិកា និងសម្ភារៈយ៉ាងច្រើន ទៅឲ្យអ្នកនយោបាយដែលមានអំណាចនិងគណបក្សកាន់អំណាច។ ថវិកាដែលបានមកពីអ្នកជំនួញទាំងនោះ ត្រូវគេយកទៅសង់សាលារៀនរាប់រយខ្នង និងសំណង់អាគារផ្សេងៗ ដែលត្រូវបានផ្សព្វផ្សាយថា ជាសមិទ្ធិផលរបស់ពួកគេ៕

## គណបក្សក្នុងរដ្ឋសភា គាំទ្រការបង្កើតច្បាប់ ហិរញ្ញវត្ថុគណបក្សនយោបាយ ពេលឃោសនាបោះឆ្នោត

## ដោយ : លីពៅ (ថ្ងៃទី26 ឧសភា 2010) រស្មីកម្ពុជា

ភ្នំពេញៈ គណបក្សនយោបាយ ដែលមានសម្លេងនៅក្នុងរដ្ឋសភា បូករួមទាំងសមាជិកសភា មកពីគណបក្សប្រជាជនកម្ពុជាដែលកំពុងតែគ្រប់គ្រងអំណាចផងបានឯកភាពនិងគាំទ្រ ឲ្យមានការបង្កើតច្បាប់ ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយ នៅពេលឃោសនាបោះឆ្នោត ។ ជំហរគាំទ្របែបនេះ ត្រូវបានសមាជិកសភា និងតំណាងមកពីគណបក្សប្រជាជនកម្ពុជា គណ បក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សជាតិនិយម ( អតីតគណបក្ស នរោត្តម រណឫទ្ធិ ) បានលើកឡើង នៅក្នុងសិក្ខាសាលា ដែលរៀបចំដោយអង្គការឃ្លាំមើលការបោះឆ្នោត ខុមហ្វ្រែល ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយ ពេលឃោសនាបោះឆ្នោត នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ នៅសណ្ឋាគារ អ៊ឹមភើរៀល ហ្គាដិន ក្នុងរាជធានីភ្នំពេញ ។ គណបក្សនយោបាយទាំង ៥ នេះ មានអាសនៈ ក្នុងរដ្ឋសភានីតិកាលទី៤ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ។

សេចក្តីប្រកាសរបស់អង្គការឃ្លាំមើលការបោះឆ្នោត ខុមហ្វ្រែល បានបង្ហាញថា ច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ នៅពេលឃោសនាបោះឆ្នោត មានសារៈសំខាន់ ក្នុងការជួយកាត់បន្ថយអំពើពុករលួយ ការទិញសន្លឹកឆ្នោត និងកំណត់នូវការចំណាយថវិការបស់គណបក្សនយោបាយ នៅពេលបោះឆ្នោតម្តងៗ ។ ច្បាប់នេះ ក៏ដើម្បីធានាឲ្យមានការប្រកួតប្រជែង ដោយយុត្តិធម៌ រវាងគណបក្ស ដែលមានធនធាន និងគណបក្ស ដែលមិនសូវមានធនធាន។ ច្បាប់ថ្មីនេះ ក៏ជាការជម្រុញ និងលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ដែលមានចែងនៅក្នុងសន្ធិសញ្ញារបស់អង្គការសហ ប្រជាជាតិ ប្រឆាំងទៅនឹងអំពើពុករលួយ ដែលប្រទេសកម្ពុជា ជាប្រទេសហត្ថលេខីមួយផងដែរ នៅក្នុងសន្ធិសញ្ញានោះ ដើម្បីឲ្យប្រជាពលរដ្ឋ មានជំនឿទុកចិត្ត មកលើការដឹកនាំរបស់គណបក្សនយោបាយ និងលទ្ធិប្រជាធិបតេយ្យ ។

សូមបញ្ជាក់ថា ច្បាប់ស្តីពីគណបក្សនយោបាយ ត្រង់មាត្រា ២៨ បានចែងថា រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នា ដល់គ្រប់គណបក្សនយោបាយ សម្រាប់ប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ ។

ក៏ប៉ុន្តែរហូតមកដល់ពេលនេះ គ្មានគណបក្សនយោបាយណា ទទួលបានថវិកាពីរដ្ឋ ដូចច្បាប់បានកំណត់ឡើយ។ ម្យ៉ាងទៀត រាល់ថវិការបស់គណបក្សនយោបាយ ដែលបានប្រើប្រាស់ក្នុងការឃោសនាបោះឆ្នោត ក្នុងពេលកន្លងមក ក៏គ្មានការត្រួតពិនិត្យឲ្យបានត្រឹមត្រូវឡើយ ៕

# បក្សនយោបាយ5គាំទ្រប្រធានបទគ្រប់គ្រងថវិកាសំរាប់ការឃោសនាបោះឆ្នោត




*ទិដ្ឋភាពរួមក្នុងសិក្ខាសាលានៅសណ្ឋាគារអីមភីរៀល*

**រាជធានីភ្នំពេញ** : តំណាងគណបក្សនយោបាយចំនួន៥ដែលមានអាសនៈនៅក្នុងសភាបានជួបជុំគ្នានៅក្នុងសិក្ខាសាលាមួយកាលពីថ្ងៃទី២៦ ឧសភា ២០១០ ដែលរៀបចំឡើងដោយគណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោតដែលបានប្រព្រឹត្តទៅនៅឯសណ្ឋាគារអីមភីរៀល ក្នុងរាជធានីភ្នំពេញ ហើយតំណាងគណបក្សដែលចូលរួមទាំងនោះបានគាំទ្រចំពោះប្រធានបទនេះ ។

លោកជាម យៀប តំណាងឱ្យគណបក្សប្រជាជនកម្ពុជា ជាអ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង និងជាប្រធានគណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភាបានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាជាគណបក្សដែលមានវ័យចំណាស់ជាងគេនៅកម្ពុជា ហើយធ្លាប់ដឹកនាំប្រទេសតែឯងជាង១២ឆ្នាំមុនកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ។ ទាក់ទងនឹងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ លោកគិតថា គណបក្សប្រជាជនកម្ពុជាអាចមានធនធានច្រើនជាងគណបក្សដទៃ ព្រោះមានអ្នកគាំទ្រជាង៥លាននាក់នៅទូទាំងប្រទេសដែលក្នុងនោះសមាជិកបក្សបានចំណាយដល់បក្សជាច្រើនបូករួមទាំងទ្រព្យសម្បត្តិរបស់បក្សមានស្រាប់តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ។ លោកជាម យៀប បានថ្លែងថាក្នុងនាមតំណាងគណបក្សប្រជាជនកម្ពុជាដែលចូលរួមសិក្ខាសាលានេះលោកគាំទ្រគោលគំនិតដែលបានលើកឡើងចង់ឱ្យមានច្បាប់គ្រប់គ្រងហិរញ្ញវត្ថុនៅពេលឃោសនាបោះឆ្នោត ។ លោកបញ្ជាក់ថា នៅពេលមានច្បាប់នេះហើយ គណបក្សដែលទទួលលុយពីរដ្ឋយកទៅឃោសនាបោះឆ្នោត តែមិនបាន១អាសនៈទេត្រូវសងលុយទៅរដ្ឋាភិបាលវិញបើមិនសងរយៈពេល៣ខែក្រោយនឹងត្រូវប្តឹងទៅតុលាការឱ្យចាត់ការ។

លោកសុន ឆ័យ តំណាងរាស្ត្រគណបក្សជំទាស់ សម រង្ស៊ី បានថ្លែងថា លោកគាំទ្រឱ្យមានច្បាប់នេះ ព្រោះថាការ ផ្តល់ជំនួយដល់គណបក្សនយោបាយពីអ្នកមានលុយអាចនឹងធ្វើការសំរេចណាមួយខុស ព្រោះនៅពេលខ្លះអ្នកមានលុយបានផ្តល់ឱ្យគណបក្សដែលឈ្នះឆ្នោតដើម្បីទទួលតំណែងផ្សេងៗ ឬទីប្រឹក្សា ថ្នាក់ដឹកនាំ ។

លោកបានថ្លែងថា នៅប្រទេសមួយចំនួនក្បែរប្រទេសកម្ពុជាដូចជាប្រទេសថៃមានច្បាប់នេះរួចមកហើយ ។ ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ឬថវិកាសំរាប់គណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោតវាមានសារសំខាន់ណាស់ ក្នុងនោះរដ្ឋអាចផ្តល់ថវិកាដល់គណបក្សតូចៗមិនសូវមានដើមទុនទៅឃោសនាទៀតផងដើម្បីឱ្យមានសមធម៌ ។

លោកទេព នន្ទារី តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងជារដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រីបានថ្លែងថា រាល់ការលើកឡើងរបស់តំណាងបក្សនយោបាយស្តីពីច្បាប់គ្រប់គ្រងថវិកាសំរាប់គណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោតដែលជាប្រធានបទនៃសិក្ខាសាលានេះលោកគាំទ្រ។ ដើម្បីកសាងប្រទេសកម្ពុជាមួយឱ្យឈានទៅដល់នីតិរដ្ឋនោះវាត្រូវមានការចូល រួមទាំងអស់គ្នា។

លោកសៅ រ៉ានី តំណាងគណបក្សជាតិនិយមអតីតគណបក្ស នរោត្តម រណឫទ្ធិ បានថ្លែងថា សិក្ខាសាលានេះមានសារសំខាន់សំរាប់កិច្ចពិភាក្សាគ្នាដើម្បីជំរុញក្នុងការស្នើសុំការឯកភាពគ្នាណាមួយក្នុងការធ្វើច្បាប់ស្តីពីការគ្រប់គ្រងថវិកាសំរាប់គណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោតនៅកម្ពុជា។ គណបក្សកាន់អំណាចមានធនធានច្រើនមានអ្នកគាំទ្រច្រើន ប៉ុន្តែគណបក្សនយោបាយតូចៗមិនសូវមានដើមទុននៅពេលឃោសនាវាមិនយុត្តិធម៌ ឬស្មើភាពទេ។

លោកយ៉ែម បុញ្ញឫទ្ធិ តំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សបានថ្លែងថា គណបក្សរបស់លោកត្រូវបានរិះគន់ថា ក្ស័យធនធាននៅពេលបក្សនេះបានបង្ហាញនូវរបាយការណ៍ចំណូលចំណាយរបស់ខ្លួនជារៀងរាល់ខែនោះ ។ លោកបុញ្ញឫទ្ធិ បន្តថា លោកគាំទ្រឱ្យមានច្បាប់ស្តីពីការគ្រប់គ្រងថវិកា

# Opposition Parties Team Up For Campaign Finance Law

By Eang Mengleng
THE CAMBODIA DAILY

Cambodia's opposition parties yesterday agreed to help draft a new election campaign finance law to reform a system they say is mired in corruption.

With the practical details of a draft left for future meetings, the parties reached the agreement at a workshop on campaign financing organized by the Committee for Free and Fair Elections.

Cheam Yeap, a lawmaker in the ruling CPP who attended the event, said he welcomed the idea.

"As I am the chairman of the [National Assembly's] Finance and Banking commission, I will review it," he said.

SRP lawmaker Son Chhay said Comfrel would help the parties draft the law.

"We have to reform this issue," insisted Mr Chhay, who accused CPP candidates of accepting campaign contributions in exchange for promises of government jobs for those who donate.

"The SRP is unhappy with government positions being connected to money," he said.

Human Rights Party lawmaker Nhem Ponharith said current laws allow for parties to draw equally from a public fund during elections but claimed that those laws had yet to actually benefit any of them.

"If we can make this law, the small parties can get a budget from the government to campaign," said Thun Saray, executive director of rights group Adhoc and a member of Comfrel's board of directors.

Funcinpec member Tep Nuonary said he hoped a new law would help counter what he described as the CPP's monopoly on media attention.

"I support the creation of this suggested law to control illegal budgets," he said. "The [ruling] party uses money illegally and there is no justice in the broadcasting or media system."

Mr Yeap suggested that any new campaign finance law require parties who draw on a public fund to repay the money if they fail to win at least 3 percent of the seats in the National Assembly.